March-2010.qxd 6/10/2010 2:51 PM Page 1

CSC
ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានកាតូលិក

# អ្នកនាំសារ
The Messenger

កាសែតចេញផ្សាយប្រចាំខែ ឆ្នាំទី៣ ថ្ងៃទី០១-៣១ ខែមីនា ឆ្នាំ២០១០ លក់តម្លៃ ១០០០រៀល តែប៉ុណ្ណោះ លេខ ៣១

## មាតិកា



អ្នកជំនាញ: "យុវជនត្រូវគិតគូរផែនការជីវិត"
ទំព័រ ៥



ស្ត្រី និងបុរស ត្រូវរួមគ្នា ទើបអភិវឌ្ឍសេដ្ឋកិច្ចរុងរឿង
ទំព័រ ៩



គំនូរទំនើបជាគំនូរច្នៃប្រឌិត
ទំព័រ ១៧

# អាងស្តុកទឹកជាជម្រើសអភិវឌ្ឍដំណាំស្រូវនៅបឹងទន្លេសាប?



កសិកម្មគឺជាវិស័យអាទិភាពមួយសម្រាប់សេដ្ឋកិច្ចកម្ពុជា។ ការអភិវឌ្ឍវិស័យកសិកម្មចាំបាច់ត្រូវយកចិត្តទុកដាក់ចំពោះបញ្ហាធារាសាស្ត្រ។ ប៉ុន្តែនៅក្នុងដំណើរការអនុវត្ត ធារាសាស្ត្រអាចប្រែប្រួលដល់បរិស្ថានរួម ឬប៉ះពាល់ប្រជាពលរដ្ឋដែរ។ ដូច្នេះទាំងអាជ្ញាធរ និងប្រជាពលរដ្ឋ អាចរួមគ្នាដោះស្រាយដោយឈរលើប្រយោជន៍រួមទាំងអស់គ្នា។ ទំព័រទី១០_១១





កម្មវិធីវិទ្យុ
**អេម៉ានូអែល** សំឡេងពីព្រះសហគមន៍កាតូលិក !
ភ្នំពេញ : FM 102.5 Mhz ម៉ោង២:០០-៣:០០ រាល់រសៀលថ្ងៃសុក្រ
បាត់ដំបង : FM 91.0 Mhz ម៉ោង ៧:៣០-៨:៣០ រាល់យប់ថ្ងៃសៅរ៍
សៀមរាប: FM 102.5 Mhz ១០:០០-១១:០០ រាល់ថ្ងៃសៅរ៍
កំពង់ធំ : FM 88.5 Mhz ម៉ោង ១២:៣០-១:៣០ ថ្ងៃសៅរ៍ថ្ងៃត្រង់
កំពង់ចាម : FM 100.5 Mhz ម៉ោង ៦:៣០-៧:០០ យប់ថ្ងៃអាទិត្យ
ក្រុងព្រះសីហនុ : FM 107.5 Mhz ម៉ោង៥:០០-៦:០០ រសៀលថ្ងៃសៅរ៍
កំពត : FM 93.25 Mhz ម៉ោង ៥:០០-៦:០០ រសៀលថ្ងៃសៅរ៍

# រូបថតប្រចាំខែ


Photo : S. Philong


Photo : S. Philong

នេះគឺទិដ្ឋភាពនៅទន្លេមេគង្គម្តុំរាជធានីភ្នំពេញ។ ទូកដែលបង្ហាញអំពីមុខរបរប្រចាំថ្ងៃរបស់ប្រជាជនឥស្លាម ដែលពឹងផ្អែកលើការនេសាទដើម្បីចិញ្ចឹមជីវិត។ នៅឆ្នាំនេះបើយោងតាមបងប្អូនឥស្លាមនៅទីនោះ ការនេសាទមិនសូវអំណោយផលប៉ុន្មានទេដោយសារតែខ្សោះខ្យល់ខុសពីធម្មតា ធ្វើឱ្យជីវភាពជួបការលំបាក។

ទោះបីមានការលំបាក ឬនឿយហត់យ៉ាងណាក៏ដោយ ក៏បងប្អូនឥស្លាមមិនភ្លេចអធិដ្ឋាន និងថ្វាយបង្គំព្រះអាឡាហ៍ខ្លួនក្នុងមួយថ្ងៃ ៥ដងដែរ។


Photo : S. Philong

អ្នកធ្វើបារីមូរដៃនៅតែខិតខំស្វែងរកទីផ្សាររបស់ខ្លួនដើម្បីចិញ្ចឹមជីវភាព ទោះបីមានការប្រកួតប្រជែងពីបារីទំនើប **(ឆ្វេង)**

ទិដ្ឋភាពរាជធានីភ្នំពេញ នៅរដូវប្រាំងមើលពីត្រើយម្ខាងនៃដងទន្លេសាប។ សំណង់ជាច្រើនកំពុងរីកដុះដាល។ **(ស្តាំ)**


Photo : S. Philong


Photo : S. Philong


Photo : S. Philong

ធុងចម្រោះទឹកស្អាតដើម្បីសុខភាព ដែលធ្វើឡើងដោយអង្គការអែរ៍ដេអុី នៅស្រុកកៀនស្វាយ ខេត្តកណ្តាល។ ធុងនេះលក់ក្នុងតម្លៃ ១0ដុល្លារ ហើយប្រជាជនកម្ពុជារកទិញបាននៅទីផ្សារទូទាំងប្រទេស។

ទឹកស្អាតចាំបាច់សម្រាប់សុខភាព។ ដូច្នេះហើយ ទើបមធ្យោបាយធ្វើទឹកឱ្យស្អាតមានសារៈសំខាន់។

March-2010.qxd 6/10/2010 2:51 PM Page 3

# វិចារណកថា

## ការតមអាហារដែលគាប់ចិត្តយើង គឺដោះលែងអ្នកត្រូវសង្កត់សង្កិន (អេសាយ ៥៨:៦)



លោកប៉ូលរឿង ឆត្រឆ័យ អ្នកសម្របសម្រួលមណ្ឌលផ្សព្វផ្សាយព័ត៌មានព្រះសហគមន៍កាតូលិក (CSC)

ជម្រាបសួរបងប្អូនជាទីស្រឡាញ់ !

រយៈពេលដ៏សំខាន់មួយនៃព្រះសហគមន៏កាតូលិកបានមកដល់ហើយ គឺ"រដូវសែសិបថ្ងៃ" ឬហៅ "រដូវអប់រំពិសេស" (ពីដើមហៅរដូវត្រណម)។ រដូវនេះមានរយៈពេល៤០ថ្ងៃដោយរាប់ពីថ្ងៃពុធ រោយផេះ (១៧-កុម្ភៈ-២០១០) រហូតដល់ថ្ងៃបុណ្យចម្លង (៤-មេសា-២០១០)។ ដោយសារ បុណ្យចម្លង (រំឭកព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញដ៏រុងរឿង) ជាបុណ្យសំខាន់បំផុតបានជាគ្រីស្តបរិស័ទ យកចិត្តទុកដាក់ ជម្រះកាយវាចាចិត្ត។ កិច្ចការមួយដែលគ្រីស្តបរិស័ទដែលមានអាយុពេញវ័យតែងតែធ្វើ គឺ "ការតមអាហារ"។

"ការតមអាហារ" មានអត្ថន័យខាងផ្លូវវិញ្ញាណដែរ គឺការអត់ធ្មត់ ហ្វឹកហ្វឺនចិត្តឱ្យចេះបង្ខាប់ខ្លួនឯងដើម្បីជាប្រយោជន៍សម្រាប់អ្នកដទៃ គឺចែកចាយប្រាក់ដែលទិញអាហារ សម្រាប់ខ្លួនខ្លះ យកទៅជួយដល់អ្នកដទៃវិញ។ ហើយកាលពីមុនព្រះយេស៊ូ ទ្រង់តមអាហារ ៤០ថ្ងៃដែរ។

គំនិតនេះនៅមានឥទ្ធិពលណាស់ សម្រាប់អភិវឌ្ឍន៍សង្គម ព្រោះសង្គមយើង មិនអាចទៅមុខបានឡើយ ប្រសិនបើមានការសង្កត់សង្កិនបរិស្ថាន និងអ្នកក្រីក្រ។

ការបៀតបៀនបរិស្ថាន គឺការយកកម្រៃពីធម្មជាតិ យ៉ាងហួសហេតុ គឺដូចការប្រើប្រាស់ធនធានធម្មជាតិ ទឹក ព្រៃឈើ ប្រេងសាំង-ល-។ តួយ៉ាងការធ្វើអាងស្តាក់ទឹក ប្រសិនបើការប្រើប្រាស់ ដោយមិនរំខានដល់ជម្រកសត្វក្នុងទឹកហួសកម្រិត មិនប៉ះពាល់បរិស្ថានខ្លាំងទេការធ្វើអាងបែបនេះអាចជាជំនួយជួយប្រជាជនក្រីក្រមែន។ ដូច្នេះត្រូវមានការចាត់ចែងយ៉ាងល្អក្នុងតំបន់នោះ និងគួរមានការសហការយ៉ាងទុកចិត្តគ្នារវាងប្រជាជន និងអាជ្ញាធរដែនដីដើម្បីដោះស្រាយបញ្ហា។

មនុស្សមានសីលធម៌ ឬមនុស្សដែលតមអាហារយ៉ាងត្រឹមត្រូវ ត្រូវតែរួមចំណែកជួយសង្គមដែរ។ បងប្អូនត្រូវតែរិះគិតថា យើងអាចជួយបន្ថយនូវការបៀតបៀនធម្មជាតិដូចម្តេច? ហើយយើងអាចជួយអ្នកដែលកំពុង ត្រូវសង្កត់សង្កិនយ៉ាងដូចម្តេចដែរ? ចម្លើយនេះអាចឃើញនៅក្នុងអំពើរបស់បងប្អូនជាពិសេសក្នុងរយៈពេល ៤០ថ្ងៃ នេះ។




## កម្មវិធីវិទ្យុព្រះសហគមន៍កាតូលិក

### អ្នកចូលរួមកម្មវិធីអេម៉ាន្ទូអែល "សម្លេងពីព្រះសហគមន៏កាតូលិក" ខែមីនា

-ថ្ងៃអាទិត្យទី៣ រដូវធម្មតា (០៧ មីនា)៖ លោកបូជាចារ្យហ្សេរ៉ាដ៍ សាសនទូតទីក្រុងប៉ារីស ព្រះសហគមន៏កំពង់ចាម។។

-ថ្ងៃអាទិត្យទី៤ រដូវធម្មតា (១៤ មីនា)៖ បងស្រីថាវីន ក្រុមគ្រួសារស្រលាញ់ព្រះឈើឆ្កាង មកពីព្រះសហគមន៏កំពង់ចាម។

-ថ្ងៃអាទិត្យទី៥ រដូវសែសិបថ្ងៃ (២១ មីនា)៖ លោកបូជាចារ្យហ្វ្រង់កូ ក្រុមគ្រួសារសាសនទូតអ៊ីតាលី ព្រះសហគមន៏កំពង់ឆ្នាំង។

-ថ្ងៃអាទិត្យទី៦ រដូវសែសិបថ្ងៃ (២៨ មីនា)៖ បងប្រុសសុខ ណា និសិត្សទេវវិទ្យាល័យ សន្តយ៉ូហាន ម៉ារី វីយ៉ាណេ។

### "ខ្ញុំត្រូវការអ្នក" ខែមីនា (FM 99.5 Mhz ច័ន្ទ,អង្គារ ម៉ោង១០-១១ព្រឹក)

ថ្ងៃទី០១ មីនា៖ ចង់មានស្នេហា។ ថ្ងៃទី០២ មីនា៖ ល្បែងស្នេហ៍សម័យទំនើប។ ថ្ងៃទី០៨ មីនា៖ សិទ្ធខ្ញុំជាយុវតី (ទស្សនៈយុវវ័យជុំវិញថ្ងៃសិទ្ធិនារីអន្តរជាតិ)។ ថ្ងៃទី០៩ មីនា៖ ឯកកោ។ ថ្ងៃទី១៥ មីនា៖ ចាំដល់ពេលណា? ថ្ងៃទី១៦ មីនា៖ ស្នេហ៍ស្មោះស្ម័គ្ររង់ចាំ។ ថ្ងៃទី២២ មីនា៖ ជម្រើសស្នេហ៍យុវវ័យ។ ថ្ងៃទី២៣ មីនា៖ គោលដៅស្នេហ៍។ ថ្ងៃទី២៩ មីនា៖ ប្រៀបធៀបស្នេហ៍។ ថ្ងៃទី៣០ មីនា៖ កលល្បិចបញ្ចប់ស្នេហ៍។ សូមបញ្ជាក់ថា ប្រធានបទទាំងនេះនឹងមានការចូលរួមបកស្រាយពីវាគ្មិនដែលមានបទពិសោធន៏ និងជំនាញច្បាស់លាស់។ **សូមកុំភ្លេចតាមដាន!**

**ការិយាល័យព័ត៌មានកាតូលិក**

ផ្ទះលេខ ២៥ ផ្លូវលេខ ២៤២ សង្កាត់បឹងព្រលិត ខណ្ឌ ៧ មករា រាជធានី ភ្នំពេញ

Tel/Fax : (855) 23 224 120;

E-mail : csccambodia@gmail.com

Website : www.catholiccambodia.org

អ្នកសម្របសម្រួល : លោកប៉ូលរឿង ឆត្រឆ័យ។ ប្រធាន : លោកលី សុវណ្ណា។

Licence ១៨៣ ពម.ប្រក. / ២៥-មិថុនា-២០០៧

# សេដ្ឋកិច្ច

## អេតចាយមុខរបរមិនអាចមើលរំលង

**ខាន់ ភីរម្យ**

ប្រធានក្រុមហ៊ុនឯកជនមួយ អះអាងថា អេតចាយជាមុខរបរមួយដែលមិនអាចមើលរំលងបាន បើទោះបីជារូបភាពខាងក្រៅ វាគឺជាមុខរបរដែលអ្នកខ្លះមិនសូវឱ្យតម្លៃ តែការពិតវាមានតម្លៃខ្លាំងណាស់ខាងពាណិជ្ជកម្ម។

លោកស្រីសៅ មឿន ជាប្រធានក្រុមហ៊ុនសៅមឿន បានមានប្រសាសន៍ថា សព្វថ្ងៃនេះ គាត់អាចបើកចេញជាក្រុមហ៊ុនអេតចាយឡើង ដោយចេញពីរទេះរុញអេតចាយ មួយតែប៉ុណ្ណោះ កាលពី ១០ ឆ្នាំមុន។ ក្រុមហ៊ុនរបស់គាត់បាននាំអេតចាយចេញមួយខែៗ រាប់សិបតោនទៅវៀតណាម និងថៃ។

សព្វថ្ងៃក្រុមហ៊ុនសៅ មឿន បានទិញអេតចាយដូចជាដែក ឈើ ស្ពាន់ អ៊ីណុក និងអាគុយ...។

លោកស្រីបានឱ្យដឹងថា សម្រាប់ផ្ទះថ្មចាស់ៗ គឺក្រុមហ៊ុនគាត់ទិញ ហើយវាយយកកំទិចថ្ម លក់ឱ្យគេដោយឡែកស្ពាន់ អ៊ីណុក និងដែក យើងប្រមូលទិញ ដើម្បីឱ្យម៉ូយយកទៅស្លឡើងវិញ។ សម្រាប់ផ្ទះឈើ គឺលោកស្រីមានដេប៉ូលក់ឈើចាស់ៗ មួយកន្លែង គឺទុកបម្រើការសំណង់ឡើងវិញ។ សម្រាប់អាគុយក៏ដូច្នេះដែរ គេទិញយកទៅរំលាយយក ជ័រ និងសំណនេះឯង។



Photo : S. Philong

លោកស្រី បានបន្តថា មើលនឹងភ្នែកផលិតផលទាំងនេះដូចគ្មានតម្លៃទេ។ តែតាមពិតវាមានតម្លៃណាស់សម្រាប់ទីផ្សារនៅក្នុងស្រុក និងនៅបរទេសជាពិសេសប្រទេសជិតខាង។

ពាក់ព័ន្ធជាមួយនឹងការនាំចេញ ក៏ដូចជាបម្រើទីផ្សារនៅក្នុងស្រុក លោកស្រីសៅ មឿន មិនមានតួលេខលំអិតទេ។ ប៉ុន្តែគាត់បានឱ្យដឹងថា នៅក្នុងមួយថ្ងៃៗ គាត់អាចប្រមូលនូវផលិតផលអេតចាយខាងលើនេះចំនួនរាប់សិបតោន រីឯការនាំចេញវិញនោះ គេមកទាក់ទងទិញផ្ទាល់ៗនៅកន្លែង សំខាន់ឱ្យតែមានផលិតផលឱ្យគេ។ លោកស្រីបានបញ្ជាក់ថា: "របស់អេតចាយដែលខ្ញុំទិញក្នុងមួយថ្ងៃ មានពី ៣តោន ទៅដល់ ៤០តោន ក៏មាន ហើយគេដឹកចេញទៅវៀតណាម និងថៃ សឹងតែមួយខែម្តង"។

លោកស្រីបានឱ្យដឹងដែរថា គាត់មិនខ្វល់ខ្វាយពីការរត់ឯកសារនាំចេញឡើយដោយសារអតិថិជនរបស់លោកស្រីគេជាអ្នករត់ការផ្ទាល់ហើយគេមានឡានមកដឹកដល់ៗកន្លែង ឱ្យតែក្រុមហ៊ុនលោកស្រីមានផលិតផលគ្រប់គ្រាន់សម្រាប់គេ។

### ជំរឿនសហគ្រាសអាជីវកម្ម

ក្រសួងផែនការនៃប្រទេសកម្ពុជា បានប្រកាសថា នឹងធ្វើជំរឿនសហគ្រាសទាំងអស់នៅក្នុងប្រទេស។ ជំរឿននេះ នឹងចាប់ផ្តើមធ្វើឡើងនៅថ្ងៃទី១ ខែមីនា ឆ្នាំ២០១១ ខាងមុខក្រោមជំនួយរបស់អង្គការ JICA ជប៉ុន។

ឯកឧត្តមឆាយ ថន រដ្ឋមន្ត្រីក្រសួងផែនការមានប្រសាសន៍ថា ជំរឿននេះគឺដើម្បីស្វែងយល់អំពីសហគ្រាសនានានៅក្នុងប្រទេសកម្ពុជា និងដើម្បីកំណត់ទីតាំងអាជីវកម្មរបស់ពួកគេ ដើម្បីងាយស្រួលធ្វើអភិវឌ្ឍន៍ផ្នែកសេដ្ឋកិច្ច និងរួមចំណែកពង្រឹងគោលនយោបាយរបស់រាជរដ្ឋាភិបាល។ ឯកឧត្តមបានឱ្យដឹងថា ជំរឿននេះនឹងចំណាយទឹកប្រាក់ប្រមាណ ៣,៥លានដុល្លារ ដោយ ២,៨លាន គឺជាជំនួយរបស់រដ្ឋាភិបាលជប៉ុនតាមរយៈអង្គការ JICA និង ៦៩៧០០០ដុល្លារ គឺជាថវិកាបដិភាគរបស់រដ្ឋាភិបាលកម្ពុជា។

# សុខភាព

## ជំងឺបេះដូងជាជំងឺមួយធ្ងន់ធ្ងរដែលគួរឱ្យព្រួយបារម្ភយ៉ាងខ្លាំងណាស់

**ជាត សំភី**

លោកវេជ្ជបណ្ឌិតហែម សុខហន នៃមន្ទីរពេទ្យកុមារជាតិ មានប្រសាសន៍ឱ្យដឹងថា:

កុមារដែលកើតមកអាចមានបញ្ហាបេះដូងមិនប្រក្រតីក្នុងអត្រាពី ៧នាក់ ទៅ៨នាក់ ក្នុងចំណោមក្មេង ១០០០នាក់។

មូលហេតុដែលបណ្តាលឱ្យមានកើតជំងឺបេះដូងមានច្រើនដូចជា ការជ្រៀតចូលរបស់មេរោគដែលធ្វើឱ្យរលាកសាច់ដុំបេះដូង ការរលាកសរសៃ បេះដូង ការរលាកបំពង់ក ដែលធ្វើឱ្យមេរោគចូល ទៅដល់បេះដូង និងធ្វើឱ្យខូចសន្ទះបេះដូង។ ចំណែកឯជំងឺរលាកសួតធ្ងន់ធ្ងរក៏អាចបណ្តាលឱ្យកើតជាជំងឺបេះដូងបានផងដែរ។



Photo : Samphy

នៅប្រទេសកម្ពុជា ជំងឺបេះដូងដែលគេជួបញឹកញាប់ជាងគេ គឺជំងឺបេះដូងពីកំណើត។ វាបណ្តាលមកពីមេរោគ។ ហើយរោគសញ្ញារបស់បេះដូង គឺកុមារមានសភាពឆាប់ហត់ជាងក្មេងនៅក្នុងអាយុដំបាលគ្នា នៅពេលពួកគេរត់លេងជាមួយគ្នា។ គេពិបាកដកដង្ហើម ដកដង្ហើមខ្លីៗ និងទឹកមុខមានសភាពស្លាំង ឡើងស្វាយដោយសារខ្វះអុកស៊ីសែន។ ដូច្នេះឪពុកម្តាយត្រូវយកចិត្តទុកដាក់សង្កេតមើល ព្រោះយើងមិនដឹងថា កុមារមានជំងឺបេះដូងដែរឬទេ?។ ប្រសិនមានអាការៈគួរឱ្យសង្ស័យ យើងត្រូវបញ្ជូនគេទៅកាន់មន្ទីរពេទ្យជាបន្ទាន់ដើម្បីឱ្យវេជ្ជបណ្ឌិតជំនាញវាស់ចង្វាក់បេះដូងថតសួត ឬធ្វើអេកូបេះដូង ដើម្បីព្យាបាលទៅតាមនោះ។

ជំងឺបេះដូងជាជំងឺមិនធម្មតាទេ។ វាអាចធ្វើឱ្យអ្នកជំងឺស្លាប់បាន បើសិនជាព្យាបាល មិនបានត្រឹមត្រូវ។ ចំណែកឯជំងឺបេះដូងចំពោះមនុស្សចាស់វិញភាគច្រើនកើតឡើងដោយសារតែគាត់មានបញ្ហាបេះដូងពីមុនមក ឬគាត់មានជំងឺលើសឈាម ដែលធ្វើឱ្យសម្ពាធឈាមឡើងខ្ពស់ប៉ះពាល់បេះដូង។

March-2010.qxd 6/10/2010 2:51 PM Page 5





Photo : S. Philong

# អ្នកជំនាញ: "យុវជនត្រូវគិតគូរផែនការជីវិត"

**ខាន់ ភីរម្យ**

ទីប្រឹក្សាឯករាជ្យខាងផ្នែកសុខភាព និងជាអ្នកជំនាញការ ខាងបញ្ហាយុវជន១រូប មានប្រសាសន៍ថា ការរៀបចំផែនការជីវិត គឺជាកត្តាដែលជំរុញឱ្យយុវជន អាចទទួលបានជោគជ័យនៅក្នុងជីវិត និងអាចគេចផុតពីបញ្ហាអសកម្មទាំងឡាយដែលយុវជនមួយចំនួនកំពុងប្រឈមនាពេលបច្ចុប្បន្ននេះ។

លោកតុង សុប្រាជ្ញ មានប្រសាសន៍បញ្ជាក់ថា: "ផែនការនេះជាគោលការណ៏តម្រង់ផ្លូវរបស់យុវជន ឈានទៅរកជោគជ័យនៅក្នុងជីវិត ហើយនិងការប្តេជ្ញាចិត្តខ្ពស់"។

តាមការអះអាងរបស់អ្នកជំនាញរូបនេះ ប្រសិនបើមនុស្សម្នាក់ៗ ពុំមានផែនការពិតប្រាកដនៅក្នុងខ្លួនទេនោះ មនុស្សម្នាក់នោះ លំបាកនឹងឈានទៅរកជោគជ័យឬធ្វើអ្វីមួយបានសម្រេចណាស់ ហើយជួនកាលវាអាចបណ្តាល ឱ្យខ្លួនពួកគេ ធ្លាក់ទៅក្នុងអំពើអសកម្មមួយចំនួន ដូចជា ញៀនគ្រឿងញៀន ជួញដូរផ្លូវភេទ និងជំងឺសង្គមជាដើម ។ល។

លោកសុប្រាជ្ញ បានឱ្យដឹងថា សម្រាប់ខ្លួន គាត់ផ្ទាល់ តាំងពីតូចរហូតដល់បច្ចុប្បន្ននេះ គឺគាត់តែងតែមានផែនការក្នុងជីវិតប្រចាំថ្ងៃជាប់ជានិច្ច ហើយដោយសារតែផែនការនេះហើយ គឺបានធ្វើឱ្យគាត់សម្រេចបានជោគជ័យលើការងារជាបន្តបន្ទាប់។ លោកបានបន្តទៀតថា រហូតមកដល់ពេលនេះជីវិតប្រចាំថ្ងៃរបស់គាត់ ដើរទៅតាមលំអាននៃផែនការដែលគាត់បានរៀបចំជានិច្ច។ លោកក៏បានបន្តថា: "ព្រលឹមឡើង ពេលខ្ញុំក្រោកពីដំណេក ខ្ញុំស្តាប់វិទ្យុទទួលទាន រួចក៏អានកាសែតមុនពេលនឹងចេញទៅបំពេញការងារ។ ល្ងាចឡើងនាពេលចប់ការងារ ខ្ញុំហាត់ប្រាណ ហើយអាចជួបនឹងមិត្តភក្តិ និងកម្មវិធីសង្គមផ្សេងៗ រួចត្រឡប់ទៅផ្ទះ"។

តាមបទពិសោធន៏របស់លោកតុង សុប្រាជ្ញ ការចេះរៀបចំផែនការប្រចាំថ្ងៃនេះគឺមិនមែនជារឿងលំបាក ប៉ុន្តែក៏វាមិនមែនជារឿងងាយស្រួលដែរ។ ដើម្បីជំរុញឱ្យផែនការនេះទទួលបាននូវជោគជ័យនោះ យុវជនក៏គួរតែចាប់ផ្តើមរៀនធ្វើផែនការ និងកំណត់គោលដៅរបស់ខ្លួន។ លោកបានបន្តទៀតថា ការធ្វើផែនការនេះ គឺមនុស្សម្នាក់ៗគួររៀនធ្វើតាំងតែពីតូច ពោលគឺគេគួររៀនរៀបចំវាតាំងតែពីថ្នាក់បឋមសិក្សាឡើងទៅ។ លោកបានបន្តថា ដើម្បីឱ្យកុមារចេះធ្វើ ផែនការនេះគឺត្រូវមានការជួយជំរុញពីឪពុកម្តាយ ពីបងប្អូន និងពីគ្រូបាធ្យាយ។

ការជំរុញឱ្យពួកគេចេះធ្វើផែនការនេះ គឺដើម្បីធ្វើយ៉ាងណាកុំឱ្យពួកគេខ្ជះខ្ជាយពេលវេលា ហើយមូលហេតុ ដែលយុវជនមួយចំនួនធ្លាក់ខ្លួន នៅក្នុងអំពើអសកម្មខាងលើនោះ គឺដោយសារតែយុវជនគាត់មានពេលវេលាទំនេរច្រើន ដែលអាចឱ្យបរិយាកាសជុំវិញ និងភាពទំនើបកម្មរបស់សង្គមអាចអូសទាញពួកគេបាន។

ចំពោះបរិយាកាសជុំវិញដែលអាចនឹងធ្វើឱ្យប៉ះពាល់ចំពោះយុវជននិងយុវនារី ដែលលោកសុប្រាជ្ញបានលើកឡើងនោះ គឺមិត្តភក្តិ និងទីកន្លែងផ្សេងៗដែលងាយស្រួល ស្វែងរកគ្រឿងស្រវឹង និងគ្រឿងញៀនដូចជាក្លឹបរាត្រី ខារ៉ាអូខេ បៀហ្គាដេនដោយសារតែលោកយល់ឃើញថា ទីកន្លែងទាំងអស់នេះកំពុងតែមានការកើនឡើង ជាពិសេសក្នុងទីក្រុងភ្នំពេញ។ ចំពោះទំនើបកម្មសម្ភារៈវិញនោះ គឺមានដូចជាទូរស័ព្ទ សម្លៀកបំពាក់ ម៉ូតូ ហើយនិងឡានជាដើម។ ដោយសារតែមានការអូសទាញ ពីកត្តាសម្ភារៈទាំងនេះ មានយុវជន និងយុវនារីជាច្រើនដែលបានខូចអនាគតរបស់ពួកគេដោយសារតែពួកគេអាចប្រើប្រាស់នូវវិធីខុសច្បាប់ដើម្បីទទួលបានសម្ភារៈទាំងនោះសម្រាប់ខ្លួនឯង។

March-2010.qxd 6/10/2010 2:51 PM Page 6

## កសិកម្ម

# ប្រព័ន្ធកសិកម្មចម្រុះនៅតាមគ្រួសារ

**ជាត សំភី**



Photo : Y. Narun

លោកអ៊ី ណារ៉ុន មន្ត្រីគ្រប់គ្រងគម្រោងមជ្ឈមណ្ឌលសិក្សា និងអភិវឌ្ឍន៍កសិកម្មកម្ពុជាសេដាក មានប្រសាសន៍ថា:

ដើម្បីរៀបចំនូវប្រព័ន្ធកសិកម្មចម្រុះជាលក្ខណៈគ្រួសារ កសិករត្រូវតែធ្វើការបែងចែកផ្ទៃដី និងធ្វើប្លង់ដាំដុះជាមុន ពីព្រោះគាត់ត្រូវដាំដុះដំណាំ ច្រើនមុខបញ្ចូលគ្នា។ គាត់ត្រូវគិតគូរថាតើផ្ទៃដីណាយកដាំដំណាំអ្វី? ពីព្រោះដំណាំវាមានប្រភេទខុសៗគ្នា ហើយពួកវា មានលក្ខណៈខុសៗគ្នាដែរ។ ដំណាំខ្លះអាយុខ្លី ខ្លះអាយុវែង។ ដំណាំខ្លះត្រូវការពន្លឺ ច្រើន ខ្លះត្រូវការពន្លឺតិច។ ដំណាំខ្លះខ្ពស់ ខ្លះទាប។

ដំណាក់កាលទីពីរ កសិករគឺគួររៀបចំដីទៅតាមប្រភេទដំណាំ។ ដំណាំខ្លះត្រូវការធ្វើដីចុះឡើងៗជាច្រើន និងត្រូវលើករងជាដើម។ បន្ទាប់មកលុះដល់ដំណាក់កាលដាំដុះ ដំណាំខ្លះត្រូវការសាប។ ខ្លះត្រូវការដាំដោយលើករង។ នាដំណាក់កាលនេះកសិករត្រូវប្រើបទពិសោធន៍ពីមុន និងការសិក្សាបច្ចេកទេសដើម្បីឱ្យបាននូវទិន្នផលខ្ពស់។ តួយ៉ាងចំពោះដំណាំ គេត្រូវការដាំឱ្យមានជួរមានបន្ទាត់ ឱ្យមានចន្លោះគុម្ពសមស្រប និងមានការគ្របគម្របដី ឱ្យបានល្អដើម្បីការពារដំណាំ និងស្មៅកុំឱ្យដុះ។

ដំណាក់កាលទីបី គឺជាដំណាក់កាលថែទាំ។ នៅដំណាក់កាលនេះ កសិករគឺត្រូវយកចិត្តទុកដាក់លើការបំប៉នជីវជាតិដី ដោយប្រើជីធម្មជាតិ ដូចជា ជីកំប៉ុសទឹក ឬក៏ធ្វើជីកំប៉ុស្តគោកជាដើម។ម្យ៉ាងវិញទៀត ថ្នាំសម្លាប់សត្វល្អិត កសិករគួរប្រើថ្នាំសម្លាប់សត្វល្អិតតាមរបៀបធម្មជាតិបានហើយ។ ចំណែករុក្ខជាតិដែលត្រូវប្រើជាថ្នាំធម្មជាតិកំចាត់សត្វល្អិតធម្មជាតិ តែង មានជាតិល្វីង ហិរ ឬចត់ មានដូចជា ស្តៅ ក្តូច ឬទន្រ្ទានខេត្តជាដើម។

ចំពោះប្រព័ន្ធកសិកម្មដំណាំចម្រុះនេះ កសិករពុំចាំបាច់ជ្រើសរើសពេលវេលាទេ សំខាន់ ឱ្យតែមានប្រភពទឹកគ្រប់គ្រាន់ និងដីដែលមានជីវជាតិ សមរម្យ និងអាចធ្វើការដាំដុះបាន។

ប្រព័ន្ធកសិកម្មដំណាំចម្រុះនៅតាមគ្រួសារនេះ មានសារប្រយោជន៍ខ្លាំងណាស់ព្រោះវាជួយកំចាត់សត្វល្អិតបានច្រើនណាស់។ ប្រព័ន្ធនេះបានជួយដល់ប្រព័ន្ធអេកូឡូស៊ីបានល្អ។ ហើយអ្វីដែលសំខាន់ជាងនេះទៀត គឺកសិករអាចរកចំណូលបាន រឹតតែច្រើនអំពីប្រព័ន្ធនេះ ពីព្រោះកសិករមានបន្លែ ឬក៏ដំណាំច្រើនមុខ ដែលធ្វើឱ្យគាត់អាច រើសយកមុខ ដែលមានតម្លៃថ្លៃលើទីផ្សារទៅលក់បាន។

## បរិស្ថាន

# កម្ពុជាផ្តើមដោះស្រាយបញ្ហាអាកាសធាតុ

រាជរដ្ឋាភិបាលកម្ពុជា ក្រោមការគាំទ្រ ពីដៃគូអភិវឌ្ឍន៍មួយចំនួនបានប្រកាសជាផ្លូវការនូវកម្មវិធី "សម្ព័ន្ធភាពការប្រែប្រួលអាកាសធាតុកម្ពុជា"



Photo : K. Phirum

ដើម្បីដោះស្រាយការប្រឈមទាំងឡាយដែលបង្កដោយការប្រែប្រួលអាកាសធាតុក្នុងប្រទេស។

ឯកឧត្តម ម៉ុក ម៉ារ៉េត ជាទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងបរិស្ថាន មានប្រសាសន៍ថា: "ការប្រកាសបើកគម្រោងនេះ ជារបត់ថ្មីមួយក្នុងការងារឆ្លើយតបនឹងការប្រែប្រួលនៃអាកាសធាតុនៅកម្ពុជា"។ លោកក៏បានបន្តទៀតថា សម្ព័ន្ធភាពនេះនឹងដើរតួឈានមុខ ក្នុងការទទួលខុសត្រូវលើការអនុវត្តឱ្យស្របតាមតម្រូវការ និងអាទិភាពរបស់ជាតិដោយធានាឱ្យបាននូវភាពជាម្ចាស់ការលើគណនេយ្យ-ភាពតម្លាភាព ប្រសិទ្ធភាព និងនិរន្តរភាព។

សម្ព័ន្ធភាពការប្រែប្រួលអាកាសធាតុកម្ពុជា គឺជាកិច្ចផ្តួចផ្តើមពហុម្ចាស់ជំនួយ ដែលបង្កើតឡើងដើម្បីពង្រឹងនូវសមត្ថភាពស្ថាប័នរបស់រដ្ឋាភិបាល អាជ្ញាធរថ្នាក់មូលដ្ឋាន និងក្រុមសង្គមស៊ីវិលដើម្បីគ្រប់គ្រងការគំរាមកំហែងដែលត្រូវបង្កើតឡើងដោយការប្រែប្រួលនៃអាកាសធាតុដើម្បីអភិវឌ្ឍប្រទេសកម្ពុជា។ កិច្ចផ្តួចផ្តើមនេះក៏បានទទួលការគាំទ្រពីមូលនិធិត្រាស់ សម្រាប់ការបម្រែបម្រួលអាកាសធាតុ ដែលមានទឹកប្រាក់សរុប ៨,៩ លាន $។ ទឹកប្រាក់នេះបានមកពីសហភាព អឺរ៉ុប ៣,២ លានដុល្លារ យូអិនឌីភី ៣លានដុល្លារ ស៊ីដា ២,១ លានដុល្លារ និងដានីដា ៥សែន ដុល្លារ។

**ខាន់ ភីរម្យ**

## អង្គការ

# "ជនពិការសតិបញ្ញាមានសេចក្តីថ្លៃថ្នូរដូចអ្នកដទៃដែរ"

**ជាត សំភី**



Photos : P. Samphy

ជនពិការដែលមានអាការៈធូរស្រាលកំពុងខិតខំសិក្សាជំនាញកាត់ដេរនៅមណ្ឌលដើម្បីចិញ្ចឹមជីវិតនៅថ្ងៃអនាគតខាងមុខ

"គាត់មានអាយុ ២៦ឆ្នាំ ហើយ តែគាត់ទើបតែចេះ ក ខ ប៉ុណ្ណោះ"។ នេះជាប្រសាសន៍របស់លោក ឃុត ថាច អ្នកបង្ហាត់មនុស្សអន់បញ្ញា នៅមណ្ឌលថែទាំ ការពារ និងតស៊ូមតិសម្រាប់ជនពិការ។

មណ្ឌលរក្សា និងគាំពារជនពិការនេះឋិតក្រោមការចាត់ចែងពីអង្គការមនុស្សលោកថ្មី ដែលបង្កើតឡើងដំបូងនៅឃុំអំពៅព្រៃ ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល។ មកដល់ពេលនេះមណ្ឌលដូចគ្នានេះបានពង្រីកចំនួន៤មណ្ឌលទៀតនៅខេត្តកំពង់ឆ្នាំងដែលមានបីមណ្ឌល នៅស្រុកបរិបូរណ៍ និងមួយមណ្ឌលនៅស្រុកកំពង់ឆ្នាំង។

លោកស៊ឹម កុសល ប្រធានកម្មវិធីថែទាំការពារ និងតស៊ូមតិសម្រាប់ជនពិការនៅអង្គការមនុស្សលោកថ្មី មានប្រសាសន៍ដែរថា កម្មវិធីមានជនពិការចំនួន៩៦នាក់។ ៣០នាក់ ស្នាក់នៅផ្ទះ។ យើងមានបុគ្គលិកយើងទៅថែទាំពួកគេ។ ក្រៅពីនេះ អ្នកខ្លះមករៀនសូត្រនៅមណ្ឌល និងត្រឡប់ទៅផ្ទះវិញ។ អ្នកខ្លះស្នាក់នៅ និងរៀនសូត្រនៅមណ្ឌលតែម្តង។

នៅបច្ចុប្បន្ននេះ ជនពិការសតិបញ្ញានៅមណ្ឌលមានអាយុចន្លោះ ពី២ឆ្នាំ ដល់ ៥០ឆ្នាំ។ ពួកគេមានការលំបាកមែនទែន។ ពួកគេមិនចេះប្រើបន្ទប់ទឹក មិនចេះហូបបាយខ្លួនឯង ឬចងចាំអ្វីក៏មិនបាន...។

ដូច្នេះហើយទើបសកម្មភាពរបស់មណ្ឌលគាំពារជនពិការខាងសតិបញ្ញានេះ មានដូចជា ការទទួលព្យាបាលដោយចលនាដល់ជនពិការ ទទួលបាយទឹក និងបង្រៀនជំនាញសង្គមឱ្យដល់ពួកគេដូចជា រៀនអក្សរ រៀនគូររូប ផាត់ពណ៌ ឬរៀនកាន់ដេរ-ល-។ មិនត្រឹមតែប៉ុណ្ណោះ មណ្ឌលក៏បានរៀបចំជាកម្មវិធីកំសាន្តដល់ជនពិការដែរ ដើម្បីដឹកនាំពួកគេឱ្យចេះធ្វើទំនាក់ទំនង ពីព្រោះជនពិការសតិបញ្ញាមានការលំបាកទំនាក់ទំនងជាខ្លាំង។

លោករ៉ូកឹប្លង់ អែររ៉េ ជានាយកប្រតិបត្តិអង្គការមនុស្សលោកថ្មីកម្ពុជា បញ្ជាក់ថា: "យើងចង់ផ្តល់សារៈសំខាន់ដល់ជនពិការ ជាពិសេសជនពិការខាងសតិបញ្ញាដោយធ្វើការពាំនាំឱ្យពួកគេនូវអ្វីៗដែលល្អសម្រាប់ជីវិត។ យើងនាំពួកគេផ្តល់ការអប់រំដល់ពួកគេដើម្បីអភិវឌ្ឍសមត្ថភាពរបស់ពួកគេ។ យើងធ្វើដូច្នេះ ពួកគេអាចចូលរួមរស់ក្នុងសហគមន៍វិញបានជាមួយនិងសេចក្តីថ្លៃថ្នូរ ក្នុងនាមជាប្រជាពលរដ្ឋ ដែលមានសិទ្ធស្មើៗគ្នា"។

# បង្រៀនដោយការលះបង់ប្រកបដោយក្តីអាណិតស្រឡាញ់

រៀងរាល់ថ្ងៃ មណ្ឌលគាំពារជនពិការសតិបញ្ញារបស់អង្គការមនុស្សលោកថ្មីនៅឃុំគោករមៀតនៃស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ដែលទើបតែផ្លាស់មកពីឃុំអំពៅព្រៃ បានបើកទ្វារទទួលបង្រៀនជនពិការ និងមើលថែពួកគេ ពីម៉ោង៨កន្លះព្រឹក ដល់ម៉ោង៣កន្លះរសៀល។

លោកស្រីញឹប សុផា ជាប្រធានមណ្ឌលនេះមានប្រសាសន៍ថាមណ្ឌលធ្វើការពីថ្ងៃចន្ទដល់ថ្ងៃសុក្រ។ សកម្មភាព នៅក្នុងមណ្ឌលមានច្រើន។ ពេលព្រឹក យើងព្យាបាលដោយចលនាដៃជើងនាំពួកគេឱ្យងូតទឹក សម្អាតខ្លួន ហាត់ប្រាណ រៀនអក្សរ ឬបង្រៀនកាត់ដេរសម្រាប់អ្នកធូរស្រាល។ ពេលល្ងាច យើងនាំពួកគេរៀនលេខ រៀនច្រៀង រៀបក្រដាស ផាត់ពណ៌រូបភាព ឬរៀបអង្កាំជាដើម។ លោកស្រីញឹម សុផាបន្តថា: "យើងបង្រៀនពួកគេទៅមុខ។ ពួកគេភ្លេចក្រោយ។ ដូច្នេះធ្វើឱ្យយើងមានអារម្មណ៍តានតឹង។ ប៉ុន្តែយើងត្រូវព្យាយាម ធ្វើកិច្ចការនេះដើម្បីអាចឱ្យពួកគេចូលរួមក្នុងសង្គមវិញ"។



ចំណែកលោកស្រីរិន សុខរី ជាអ្នកគ្រូម្នាក់ទៀតនៅមណ្ឌលគោករមៀតនេះ ក៏បានប្រាប់ឱ្យដឹងថា មនុស្សអាប់ប្រាជ្ញាខុសពីអ្នកធម្មតាសឹងតែ ៩០%។ ពួកគេមិនចេះលាងដៃមិនចេះហូបចុក មិនចេះប្រើបន្ទប់ទឹក ឬពេលយើងនិយាយស្តី គេក៏មិនយល់។ ប៉ុន្តែយើងក៏នៅតែខំមើលថែគេដោយក្តីអាណិតស្រឡាញ់ដែរ។ ចំណែកលោកឃុត ថាច ជាគ្រូម្នាក់ទៀត មានប្រសាសន៍ក្នុងន័យស្រដៀងគ្នានេះដែរថា: "យើងត្រូវតែខំបង្រៀនគេ ព្រោះកូនគេក៏ដូចជាកូនយើង។ លោកបានសំណូមពរទៅដល់ប្រជាជនទាំងអស់ សូមកុំឱ្យរើសអើងជនពិការ សូមជួយប្រាប់គ្នា និងជួយគ្នា ពីព្រោះយើងជាមនុស្សដូចគ្នា គ្រាន់តែពួកគេអន់បញ្ញាប៉ុណ្ណោះ។

# ព័ត៌មានទូទៅ



Photos : DR

## របាំសហសម័យ

កាលថ្ងៃទី១២ កុម្ភៈ កន្លងទៅនេះ មានការប្រគុំរបាំសហសម័យ ដែលរៀបចំឡើងដោយក្រុមរបាំបុរាណ វិទ្យាល័យសិល្បៈ និងក្រោមការឧបត្ថម្ភពីស្ថានទូតបារាំង មជ្ឈមណ្ឌលវប្បធម៌បារាំង និងអម្រឹតាសិល្បៈ។

អ្នកគ្រូសុទ្ធ សុម៉ាលី ជាប្រធានក្រុមរបាំបុរាណនៃវិទ្យាល័យសិល្បៈ មានប្រសាសន៍ថា នៅប្រទេសគេល្បីៗ គេមានការច្នៃប្រឌិតពីរបាំបុរាណ ដោយភ្ជាប់ជាមួយភ្លេងសម័យ ដោយឡែកនៅស្រុកយើងគឺមិនទាន់មាន។ កាលពីមុនគ្រូរបាំបាឡេ ដែលមកពីប្រទេសបារាំងសាកល្បងបញ្ចូលក្បាច់បាឡេជាមួយក្បាច់ខ្មែរយើង។

របាំសហសម័យនេះ គឺយើងយកភ្លេងបរទេសតាមរយៈការកូតវិយូឡុងសែដោយលោកវ៉ាំងសង់ កូរទ័ត និងផ្សំជាមួយ ភ្លេងខ្មែរបែបចង្វាក់ញាប់ៗ។ ការសម្តែងនេះ និងមានជាថ្មីម្តងទៀតនៅថ្ងៃទី២៨ កុម្ភៈ ឆ្នាំ ២០១០ នៅទីលានវត្តបុទមវត្តី។

## ជប៉ុនជួយ ៥,៥លានដុល្លារ ដល់សកម្មភាពដោះមីននៅកម្ពុជា

រាជរដ្ឋាភិបាលប្រទេសជប៉ុន បានសម្រេចផ្តល់ជំនួយសរុប ៥,៥លានដុល្លារដល់កម្ពុជា ដើម្បីបន្តសកម្មភាពដោះ និងបោសសំអាតមីនដែលបន្សល់ទុកដោយសារតែសង្គ្រាមស៊ីវិល។ នៅក្នុងរង្វង់ទឹកប្រាក់ ៥,៥លានដុល្លារនេះ គឺរួមមានម៉ាស៊ីនរាវមីនចំនួន ៤៨៨គ្រឿង ម៉ាស៊ីនរាវគ្រាប់មីនជម្រៅជ្រៅ មានចំនួន ៤៤គ្រឿង ព្រមទាំងគ្រឿងបន្លាស់ គ្រឿងចក្រសម្រាប់កំទេចមីន និងរោងជាងជួសជុលចល័តមួយចំនួនផងដែរ។

ជំនួយនេះត្រូវបានចុះហត្ថលេខាទទួលនៅក្រោមអធិបតីភាពរបស់សម្តេចហ៊ុន សែនប្រមុខរដ្ឋាភិបាលកម្ពុជា និងឯកអគ្គរាជទូតប្រទេសជប៉ុនប្រចាំនៅក្នុងប្រទេសកម្ពុជាកាលពីថ្ងៃទី១៧ ខែកុម្ភៈ កន្លងទៅ។

ជំនួយនេះគឺជាទឹកប្រាក់ជំនួយលើកទី៥ របស់រាជរដ្ឋាភិបាលជប៉ុនដែលបានជួយដល់មជ្ឈមណ្ឌលបោសសំអាតមីនកម្ពុជា។

ដោយសារតែសង្គ្រាមស៊ីវិលកម្ពុជាបានបន្សល់ទុកនូវគ្រាប់មីន និងគ្រាប់មិនទាន់ផ្ទុះរាប់លានគ្រាប់នៅពាសពេញប្រទេស ជាពិសេស នៅតាមបណ្តាខេត្តជាប់ព្រំដែនថៃ។

## កម្ពុជាត្រូវការថវិកា ១៤០លានដុល្លារ ដើម្បីស្តារគ្រោះមហន្តរាយដោយសារព្យុះ

បើតាមតុល្យការចុងក្រោយរបស់គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយបង្ហាញថា ព្យុះកេតសាណាដែលបានបោកបក់កម្ពុជា កាលពីចុងឆ្នាំ២០០៩កន្លងទៅ បានបំផ្លាញអស់ទឹកប្រាក់ទំហំ ១៤០លានដុល្លារ។

លោកពៅ សាមី អគ្គលេខាធិការនៃគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ មានប្រសាសន៍ថា ដើម្បីដោះស្រាយបញ្ហានេះ រាជរដ្ឋាភិបាលត្រូវការថវិកាប្រមាណ ១៤០ លាន ដុល្លារដើម្បីស្តារការខូចខាត។

តាមប្រសាសន៍របស់លោកសាមី ម្ចាស់ជំនួយដែលបានសន្យាលើកម្មវិធីស្តារការខូចខាតដោយសារតែគ្រោះមហន្តរាយ ធម្មជាតិនេះ គឺមានធនាគារពិភពលោក ប្រទេសចិន និងប្រទេសកូរ៉េខាងត្បូង។

ព្យុះកេតសាណា បានបោកបក់មកកម្ពុជាកាលពីថ្ងៃទី២៨ និង២៩ ខែកញ្ញា ឆ្នាំ ២០០៩ ដោយប៉ះពាល់ដល់ខេត្តចំនួន ១១ និងសម្លាប់ជីវិតមនុស្សអស់ចំនួន ៣៥នាក់។

## ២១លាននាក់ធ្លាក់ខ្លួនក្រ ដោយវិបត្តិសេដ្ឋកិច្ចពិភពលោក



អង្គការសហប្រជាជាតិ បានអះអាង កាលពីថ្ងៃទី១៩ កុម្ភៈ កន្លងទៅថា វិបត្តិសេដ្ឋកិច្ចពិភពលោកបានរុញច្រានប្រជាពលរដ្ឋនៅតំបន់អាស៊ី និងប៉ាស៊ីហ្វិក ចំនួន២១លាននាក់ធ្លាក់ខ្លួនក្រ។

បណ្តាញព័ត៌មានប្លូមប៊័រដកស្រង់របាយការណ៍នោះថា វិបត្តិសេដ្ឋកិច្ចនេះនឹងជះឥទ្ធិពលអវិជ្ជមានដល់គោលដៅអភិវឌ្ឍន៍សហសវត្សរ៍ដែលគ្រោងនឹងកាត់បន្ថយភាពក្រីក្រឱ្យបាននៅមុនឆ្នាំ២០១៥នោះ។

លោកអាហ្សាយ ឈីប៊័រ នាយកកម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិប្រចាំតំបន់អាស៊ីប៉ាស៊ីហ្វិកបានឱ្យដឹងដែរថា: "អាស៊ីគឺជាប្រជាជាតិដែល មានការគាំពារសង្គមទន់ខ្សោយបើប្រៀបធៀបនឹងតំបន់ផ្សេងៗ ដោយរួមទាំងតំបន់នៅអាម៉េរិកឡាទីនផងដែរ"។ លោកក៏បានបន្ត ឱ្យដឹងទៀតថា ប្រសិនបើមិនមានការគាំទ្រផ្នែកសង្គមកិច្ច ដល់ប្រជាពលរដ្ឋឱ្យបានរឹងមាំទេនោះ ភាពក្រីក្រ ការរីករាលដាលជំងឺឆ្លង និងគ្រោះមហន្តរាយធម្មជាតិផ្សេងៗជាដើមនោះ នឹងមិនងាយស្រួលនៅក្នុងការស្តារឡើងវិញនោះទេ។

## ធនាគារពិភពលោកជំរុញឱ្យវិនិយោគលើវិស័យកសិកម្មនៅអាហ្វ្រិក

របាយការណ៍អភិវឌ្ឍន៍ពិភពលោកមួយរបស់ធនាគារពិភពលោកបានជំរុញឱ្យពិភពលោកបង្កើនការវិនិយោគទៅលើវិស័យកសិកម្មនៅបណ្តាប្រទេសនៅទ្វីបអាហ្វ្រិក។

ប្រភពដដែលនោះ បានឱ្យដឹងដែរថា វិស័យកសិកម្មនេះត្រូវតែដាក់ចេញនៅក្នុងរបៀបវារៈនៃការអភិវឌ្ឍក្នុងតំបន់ ប្រសិនបើបណ្តាប្រទេសនៅក្នុងតំបន់ចង់សម្រេចនូវគោលដៅនៃការអភិវឌ្ឍសហសវត្សរ៍នៅក្នុងឆ្នាំ២០១៥។

មកដល់ពេលនេះរបាយការណ៍បានឱ្យដឹងថា នៅក្នុងចំណោមបណ្តាប្រទេសនានានៅអាហ្វ្រិក អនុតំបន់សាហារ៉ាជាតំបន់ដែលវិស័យកសិកម្មដើរនៅពីក្រោយតំបន់នានានៅលើពិភពលោក។

ប្រភពដដែលនោះបានបន្តទេថា វិស័យកសិកម្មនៅក្នុងបណ្តាប្រទេសនៅមហាអនុតំបន់សាហារ៉ា បានផ្តល់នូវការងារដល់ប្រជាពលរដ្ឋប្រមាណ ៦៥% នៃកម្លាំងពលកម្មសរុប។ ប៉ុន្តែវាបានរួមចំណែកនៅក្នុងអត្រាកំណើននៃផលិតផលនៅក្នុងស្រុកសរុបត្រឹមតែ៣២% ប៉ុណ្ណោះ។ បច្ចុប្បន្ននេះ មហាអនុតំបន់សាហារ៉ា មានប្រជាជនប្រមាណ២២៩លាននាក់ មានសភាពក្រីក្របំផុត។

**ខាន់ ភីរម្យ**

March-2010.qxd 6/10/2010 2:51 PM Page 9



# ស្ត្រី និងបុរសត្រូវពួតដៃគ្នា ទើបអភិវឌ្ឍសេដ្ឋកិច្ចបានរុងរឿង

**ខាន់ ភីរម្យ**

*ថ្ងៃទី០៨ ខែមីនា នេះ គឺជាទិវាសិទ្ធិនារីនៅទូទាំងពិភពលោក។ ដូច្នេះដើម្បីដឹងថា តើសិទ្ធិនារីនៅក្នុងសង្គមកម្ពុជាមានស្ថានភាពយ៉ាងណានោះ? អ្នកនាំសារសូមណែនាំមិត្តអ្នកអានឱ្យជួបនូវបទសម្ភាសន៍ជាមួយនឹងលោកស្រីហ៊ុន ផាណ្ណា ប្រធានស្តីទីនៃអង្គការអភិវឌ្ឍន៍ស្ត្រីកម្ពុជា។*

**អ្នកនាំសារ: តើស្ថានភាពនៃការចូលរួមរបស់ស្ត្រីនៅក្នុងដំណើរការអភិវឌ្ឍន៍ប្រទេស ក៏ដូចជាសង្គមជាតិនៅក្នុងប្រទេសកម្ពុជានាបច្ចុប្បន្នកាលនេះមានសភាពយ៉ាងណាដែរ?**

**លោកស្រីហ៊ុន ផាណ្ណា** : ខ្ញុំមិនមានស្ថិតិដើម្បីបង្ហាញទេ។ ប៉ុន្តែជាទូទៅខ្ញុំយល់ឃើញថា ការចូលរួមរបស់ស្ត្រីនៅក្នុងដំណើរការអភិវឌ្ឍសង្គមនៅក្នុងប្រទេសកម្ពុជានាពេលបច្ចុប្បន្ននេះ មានការរីកចម្រើនច្រើន ប្រសិនបើប្រៀបធៀបនឹងរយៈពេលកន្លងមក។ ខ្ញុំទទួលស្គាល់ថា នៅក្នុងមជ្ឈដ្ឋាន អ្នកដឹកនាំជាពិសេសសម្រាប់ខាងផ្នែកនយោបាយ ការចូលរួមរបស់ស្ត្រីនៅមានកម្រិត។ ប៉ុន្តែសម្រាប់នៅក្នុងសង្គមសេដ្ឋកិច្ចវិញ យើងក៏មើលឃើញថា ស្ត្រីមានការចូលរួមច្រើនណាស់ ហើយការចូលរួមនេះគឺរឹតតែច្រើនជាងពីមុនទៅទៀត។



Photo : DR

បាតុកម្មតស៊ូដើម្បីសិទ្ធិស្ត្រីកាលពីពេលកន្លងទៅ

**អ្នកនាំសារ : លោកស្រីបានមានប្រសាសន៍អំពីអតុល្យភាពរបស់ស្ត្រីនៅក្នុងការចូលរួមដំណើរការអភិវឌ្ឍន៍ តើអ្វីទៅជាឧបសគ្គ ដែលធ្វើឱ្យស្ត្រីនៅតែមិនទាន់មានតុល្យភាពនៅក្នុងសង្គម?**

**លោកស្រីហ៊ុន ផាណ្ណា** : មកដល់ពេលបច្ចុប្បន្ននេះរដ្ឋាភិបាលកម្ពុជាបានទទួលស្គាល់ថារាល់គោលនយោបាយអភិវឌ្ឍន៍ ប្រទេសជាតិ គឺត្រូវការមានការចូលរួមពីស្ត្រី។ តែបញ្ហាដែលធ្វើឱ្យស្ត្រីមិនអាចចូលរួមបានយ៉ាងទូលំទូលាយនោះ គឺដោយសារតែស្ត្រីមានចំណេះដឹងនៅទាប។ តែប្រសិនបើស្ត្រីភាគច្រើនគាត់មានចំណេះដឹងខ្ពស់វិញ នេះនឹងធ្វើឱ្យការចូលរួមរបស់គាត់នៅក្នុងសង្គមបានច្រើន និងទទួលបានការទទួលស្គាល់។ ប៉ុន្តែនៅក្នុងប្រទេសចំណេះដឹងរបស់ស្ត្រីភាគច្រើន គឺនៅមានកម្រិត។

**អ្នកនាំសារ : តើត្រូវធ្វើយ៉ាងណាដើម្បីជំរុញឱ្យមានការចូលរួមរបស់ស្ត្រី និងបុរស នៅក្នុងដំណើរការអភិវឌ្ឍទាំងអស់គ្នា?**

**លោកស្រីហ៊ុន ផាណ្ណា**: រដ្ឋាភិបាល និងសង្គមស៊ីវិលគួរជំរុញកម្មវិធីអប់រំក្រៅប្រព័ន្ធ ជាពិសេសលើកម្មវិធីអនក្ខរកម្ម ហើយស្ត្រីខ្លួនឯងត្រូវតែយល់ពីតម្លៃសម្រាប់ការចូលរួមរបស់ខ្លួនផងដែរនៅក្នុងការអភិវឌ្ឍសេដ្ឋកិច្ចរបស់ប្រទេសជាតិ។

**អ្នកនាំសារ : តើវិស័យណាមួយក្នុងសង្គមដែលការចូលរួមរបស់ស្ត្រីមានលក្ខណៈលេចធ្លោជាងគេមកដល់ពេលនេះ?**

**លោកស្រីហ៊ុន ផាណ្ណា**: មកដល់ពេលនេះ ខ្ញុំគិតថា វិស័យដែលស្ត្រីភាគច្រើន មានការចូលរួមធ្វើសកម្មភាពដ៏ច្រើនលើសលុបនោះ គឺមានវិស័យកសិកម្ម និងអាជីវកម្មខ្នាតតូច។ នៅតំបន់ជនបទក្រៅពីកិច្ចការជាមេផ្ទះ ស្ត្រីជាសកម្មជនដ៏មោះមុតនៅក្នុងវិស័យកសិកម្ម ដូចជាការធ្វើស្រែចំការច្បារដំណាំ។ តែនៅទីក្រុងគឺជាមុខរបរតូចតាច។ ជាក់ស្តែងនៅតាមទីផ្សារ តើមានបុរសប៉ុន្មាននាក់ ដែលចេញ ទៅបើកហាងលក់ដូរ ឬទូលកញ្ច្រែងលក់បន្លែ ឬទំនិញទៅ។ នេះជាឧទាហរណ៍ជាក់ស្តែងមួយនៃការចូលរួម និងតួនាទីរបស់ស្ត្រីនៅក្នុងការអភិវឌ្ឍសង្គមជាតិ និងសង្គមគ្រួសារ។



Photo : DR

ការប្រជុំសមាជិកក្រុមប្រចាំខែនៅភូមិកំរៀង សង្កាត់ព្រៃវែង ខណ្ឌដង្កោ រាជធានីភ្នំពេញ នៅក្នុងកម្មវិធីគម្រោងសុខភាពមាតា និងកុមារ ដែលរៀបចំឡើងដោយអង្គការអភិវឌ្ឍន៍ស្ត្រីកម្ពុជា

### លើកកម្ពស់សមភាពយ៉េនឌ័រ

លោកជំទាវម៉ែន សំអន ឧបនាយករដ្ឋមន្ត្រីនៃប្រទេសកម្ពុជា បានអះអាងកាលពីថ្ងៃទី១១ ខែកុម្ភៈ កន្លងទៅនៅក្នុងខេត្តសៀមរាបថា វិសមភាពយ៉េនឌ័រនៅតែមាន។ ប៉ុន្តែរដ្ឋាភិបាលនៅតែបន្តខិតខំប្រឹងប្រែងដើម្បីលើកកម្ពស់សមភាពនេះបន្តទៀត។

លោកជំទាវបញ្ជាក់ថា: “៨០%នៃកម្លាំងការងារសរុប និង ៨៣%នៃស្ត្រីពេញកម្លាំងធ្វើការស្ថិតនៅក្នុងវិស័យសេដ្ឋកិច្ចមិនផ្លូវការ ជាអ្នកប្រកបរបរខ្លួនឯង ឬជាអ្នកធ្វើការមិនមានប្រាក់ឈ្នួល”។ លោកជំទាវបន្តទៀតថា ដើម្បីកាត់បន្ថយភាពក្រីក្រនៅតាមតំបន់ជនបទ ការធានាឱ្យមានការងារសមរម្យ និងពង្រីកឱកាសសម្រាប់ស្ត្រីនៅទីកន្លែងទាំងនោះ គឺជាគោលការណ៍របស់រដ្ឋាភិបាល។

March-2010.qxd 6/10/2010 2:51 PM Page 10



# តើអាងស្ទាក់ទឹកជាជម្រើសអភិវឌ្ឍដំណាំស្រូវជុំវិញបឹ

**ខាន់ ភីរម្យ**

នៅតំបន់មួយចម្ងាយប្រមាណជាជិត ៤០គីឡូម៉ែត្រពីមាត់បឹងទន្លេសាបក្នុង ភូមិសាស្ត្រស្រុក ៥ នៃខេត្តកំពង់ធំ គឺ ស្រុកបារាយ ស្ទោង សន្ទុក ស្ទឹងសែន និងកំពង់ស្វាយ គេឃើញមានទួរផ្លូវខ្វាត់ខ្វែងវាលស្រែដែលមានស្រូវកំពុងតែរីកលូតលាស់ខៀវស្រងាត់នៅលើផ្ទៃដីធំៗ គឺខុសប្លែកពីវាលស្រែនៅកន្លែងដ៏ទៃ។ ក្រៅពីវាលស្រែ គេឃើញមានផ្ទៃដីព្រៃលិចទឹកដែលស្ថិតនៅព័ទ្ធជុំវិញទៅដោយផ្លូវលំដែលមើលទៅប្រៀបបាននឹងការលើកទំនប់។

តំបន់នោះ ទាំងមូលត្រូវបានអ្នកស្រុក អះអាងថា ជាតំបន់វាលស្រែប្រាំង ដែលពួកគេកំពុងតែធ្វើស្រែពូជស្រូវប្រដេញទឹក ដោយពឹងផ្អែកទាំងស្រុងលើទឹកអាងដែលកសាងឡើងដោយសហគមន៍។

លោកហង់ សុគន្ធ ជាប្រធានសមាគមអភិវឌ្ឍន៍ស្រែប្រាំងកម្ពុជា ក៏មានប្រសាសន៍ថា ស្រុកទាំង ៥ នោះ មានអាងស្ទាក់ទឹកទាំងអស់ ៨៤អាង ហើយអាចមានលទ្ធភាពស្រោចស្រពលើផ្ទៃដីស្រែប្រាំងចំនួន ២៦០០០ហិចតា។ ហើយក្នុងមួយឆ្នាំ កសិករប្រមាណជា ៧០០០គ្រួសារ មានលទ្ធភាពផលិតជាស្រូវចេញមកពីតំបន់នោះប្រមាណ១៣ម៉ឺនតោន។ លោក ក៏បានបញ្ជាក់ថា: "ផ្ទៃដីនៅទីនោះ កសិករអាចបង្កបង្កើនផលស្រូវតាមវិធីពង្រួស ដោយមិនចាំបាច់ស្ទូង ហើយក៏ទទួលផលប្រមាណពី ៥តោនទៅ ៧តោន ក្នុងមួយហិចតា"។

តាមប្រសាសន៍លោកសុគន្ធ ផ្ទៃដីទាំង២៦០០០ហិចតានោះ បានចាប់ផ្តើមផលិតស្រូវដំបូង នៅឆ្នាំ ២០០៤ ដោយពឹងទាំងស្រុងលើទឹកពីអាងស្ទាក់ទឹកដែលត្រូវបានកសាងឡើងដោយសហគមន៍ផ្ទាល់ ឬដោយសកម្មភាពវិនិយោគទុនខ្នាតតូច ក្រោមកិច្ចសហការរវាងកសិករ និងអ្នកវិនិយោគ។ លោកក៏បញ្ជាក់ថា: "តាមខ្ញុំដឹង អាងខ្លះ គឺកើតដោយសារសហគមន៍រួមគ្នារាប់រយគ្រួសារកសាង។ ហើយខ្លះទៀតធ្វើ ក្រោមរូបភាពកសិករមានដី និងអ្នកវិនិយោគមានលុយគេរួមគ្នាកសាង និងចែកផលគ្នា"។

ការបែងចែកផលប្រយោជន៍ រវាងកសិករ និងអ្នកវិនិយោគ ធ្វើឡើងដោយការដោះដូររវាងស្រូវពី៧០០គីឡូក្រាមទៅ១តោនក្នុងមួយឆ្នាំ ជាថ្នូរនឹងទឹកស្រោចស្រពផ្ទៃដី១ហិចតាក្នុងមួយឆ្នាំដែរ។



Photo : H. Sotheary

## អាងទាំងអស់នៅកំពង់ធំផ្តល់ចំណូលចំនួនជាង៥លានដុល្លារ

**ឯកឧត្តមលឹម គានហោ រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម មានប្រសាសន៍ថា ផ្ទៃអាងដែលក្រសួងចុះសិក្សា មានចំនួន ៨២អាង។ នៅក្នុងលិខិតមួយមួយគោរពជូនប្រមុខរដ្ឋាភិបាលកម្ពុជា កាលពីថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៩ កន្លងទៅ របស់ឧត្តម បានឱ្យដឹងថា អាងទាំងអស់នេះ អាចរកចំណូលប្រមាណ ៣៣៦០២៤០ដុល្លារ ពីការធ្វើស្រែ ហើយនិងចំណូលប្រមាណ ២៣១៨០០០ដុល្លារ ពីការនេសាទក្នុងមួយឆ្នាំ។ ប៉ុន្តែផលប្រយោជន៍ទាំងអស់បានទៅដល់ដៃតែឈ្មួញប៉ុណ្ណោះ។**

**លោកអះអាងថា អាងទាំងនេះប៉ះពាល់ដល់ធនធាន និងរបបជលសាស្ត្រ។ ដូច្នេះក្រសួងសំណូមពរឱ្យរំលាយចោលអាងស្ទាក់ទឹកទាំងអស់នេះ។ ហើយនៅថ្ងៃទី១២ វិច្ឆិកាឆ្នាំដដែល ទីស្តីការគណៈរដ្ឋមន្ត្រីបានចេញសេចក្តីជូនដំណឹងឱ្យលុបចោលអាងទាំងអស់នេះ ដោយជំហានដំបូងគឺរំលាយអាងចំនួន ១៦សិន។**

លោកសុគន្ធបានឱ្យដឹងដែរថា ការធ្វើដូច្នេះ ជូនកាល មានទំនាស់ខ្លះ។ ប៉ុន្តែរហូតមកដល់ពេលនេះ សហគមន៍ គឺអាចសម្របសម្រួលការងារ និងជំរុញល្បឿនផលិតដំណាំស្រូវ ដើម្បីបំពេញនូវមហិច្ឆិតារបស់រដ្ឋាភិបាលក្នុងការប្រែក្លាយប្រទេសកម្ពុជាឱ្យទៅជាប្រទេសអ្នកនាំចេញអង្ករមួយដ៏សំខាន់។

លោកអ៊ុំ សាមហាក់ អាយុ ៧៥ឆ្នាំ គឺមកពីភូមិឃុំសែនគរ ស្រុកកំពង់ស្វាយ បានមានប្រសាសន៍ថា ដោយសារ ស្រែរបស់គាត់ចំនួន ២ហិចតា ដែលរដ្ឋចែកឱ្យនោះ មិនអាចឱ្យផលគ្រប់គ្រាន់សម្រាប់ទ្រទ្រង់ជីវភាពបាន។ គាត់ និងបងប្អូន ៦គ្រួសារទៀតបាននាំគ្នាមកធ្វើស្រែនៅទីនេះ លើដី១០ហិចតា បីឆ្នាំមកហើយ និងទទួលបានផលជាមធ្យម ៥តោនក្នុងមួយហិចតា ដែលធ្វើឱ្យគាត់មានធនធានគ្រប់គ្រាន់សម្រាប់រស់បានសមរម្យល្អប្រសើរជាងមុន។ លោកអ៊ុំបានបញ្ជាក់ថា: "ពីមុន ខ្ញុំរកតែអង្ករច្រក

# ជុំវិញបឹងទន្លេសាប ?



ឆ្នាំងសឹងមិនបាន។ ប៉ុន្តែពេលនេះ ខ្ញុំមានគោយន្ត ម៉ូតូ ឬទូរទស្សន៍ គ្រាន់នឹងមើលដូចគេដូចឯង"។

លោកពូសែម ស៊ិយ អាយុ ៥៥ឆ្នាំ កសិករភូមិ-ពោធិ៍សែន ស្នាយ ឃុំតាញូវ ក្រុងស្ទឹងសែន បានឱ្យដឹងថា គាត់មានផ្ទៃដី១៥ហិចតា។ ហើយគាត់តែងតែនាំគ្រួសារមករស់នៅវាលស្រែនេះ ប្រមាណជា ៥ខែ។ លោកពូស៊ិយ ក៏បានឱ្យដឹងថា គាត់បោះបង់ផ្ទៃដីស្រែលើអស់ហើយ ដោយសារតែវាឱ្យផលតិចពេក។ លោកបានបញ្ជាក់ថា: "ស្រែពីខាងលើ ដីវាហិល ១ហិចតាឱ្យផលសឹងមិនដល់ ២០០ថាំងផង។ នៅទីនេះ ១ហិចតា បានពី ៥-៦ តោន ឯណោះ"។

លោកសុគន្ធបានឱ្យដឹងដែរថា តំបន់ស្រែនេះជាតំបន់ដែលមានសក្តានុពលបំផុត សម្រាប់សេដ្ឋកិច្ចខេត្ត ផ្តល់ប្រយោជន៍ដល់សេដ្ឋកិច្ចរដ្ឋ និងប្រជាជនច្រើនជាងការនេសាទទៅទៀត។ លោកបញ្ជាក់ថា: "របាយការណ៍ខេត្តបានឱ្យដឹងថា ខេត្តកំពង់ធំ មានផ្ទៃដីឡូត៍នេសាទ សរុបចំនួន ១២៧០គម² បង់ពន្ធជូនរដ្ឋបានត្រឹមតែ៧៨លានរៀលទេ។ តែផ្ទៃដីស្រែប្រាំងចំនួន១០០គម² អាចឱ្យកសិកររកចំណូលបានប្រមាណជា ១៥ម៉ឺនដុល្លារ ក្នុងមួយឆ្នាំ"។

ពាក់ព័ន្ធនឹងការបង្កបង្កើនផលស្រូវដោយប្រើប្រាស់ទឹកពីអាងស្ទាក់ទឹកនេះ លោកសុគន្ធ បានអះអាងថា: "នេះជាបទពិសោធន៍ ដែលខ្ញុំគិតថា អាចយកមកអនុវត្តន៍នៅបណ្តាខេត្តជុំវិញបឹងទន្លេសាបបាន"។ លោកបានបន្តទៀតថា នៅខាងតាកែវ គេមានបទពិសោធន៍បុកអណ្តូង ដើម្បីធ្វើស្រែ។ ប៉ុន្តែសម្រាប់នៅកំពង់ធំ និងខេត្តជុំវិញបឹងទន្លេសាប គឺគួរប្រើប្រាស់បច្ចេកទេសធ្វើអាងស្ទាក់ទឹកនេះ។

បើតាមប្រសាសន៍របស់លោកប្រធានសមាគមអភិវឌ្ឍន៍ស្រែប្រាំងកម្ពុជា ការធ្វើអាងស្តុកទឹកនេះជាសក្តានុពលមួយសម្រាប់អភិវឌ្ឍន៍វិស័យកសិ-កម្មនៅប្រទេសកម្ពុជា។ ប៉ុន្តែកាលពីចុងឆ្នាំ២០០៩កន្លងទៅ ក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទបានស្នើសុំឱ្យមានការលុបចោលអាងទឹកទាំងអស់នោះដោយអះអាងថា វាប៉ះពាល់លើធនធានជល-ផល និងប៉ះពាល់ដល់របបជលសាស្ត្រដែលអាចនឹងធ្វើឱ្យអន្តរាយចំពោះព្រៃលិចទឹក ទាំងសត្វល្អូន និងជីវចម្រុះផ្សេងៗទៀត។

ផ្អែកតាមរបាយការណ៍ក្រសួងកសិកម្ម សម្តេចហ៊ុន សែន នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាល កម្ពុជាបានធ្វើចំណារមួយកាលពីថ្ងៃទី០៩ តុលា ឱ្យក្រសួងធនធានទឹក និងឧតុនិយម ចុះធ្វើការសិក្សាបន្ថែម ហើយនៅថ្ងៃទី១៩ តុលា ឯកឧត្តម លឹម គានហោ រដ្ឋមន្ត្រីក៏បានឯកភាពនឹងសំណើរបស់ក្រសួងកសិ-កម្មឱ្យលុបចោលអាងទាំងអស់នោះ។

ផ្អែកទៅតាមរបាយការណ៍របស់ក្រសួងជំនាញទាំងពីរកាលពីថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០០៩ កន្លងទៅនេះ ទាក់ទងនឹងករណីសភាពការនៃបញ្ហាអាងទឹក ក្នុងតំបន់ព្រៃលិចទឹក និងតំបន់ស្រូវឡើងទឹកក្នុងភូមិសាស្ត្រ ខេត្តកំពង់ធំ ទីស្តីការគណៈរដ្ឋមន្ត្រីបានចេញសេចក្តីជូនដំណឹងមួយ បានយល់ព្រមលុបចោលអាងទាំងអស់នោះ ហើយជាជំហានដំបូង គឺលុបចោលអាង ចំនួន១៦ សិន។

នៅជុំវិញការសម្រេចរបស់ក្រសួងជំនាញទាំងពីរនេះ លោកសុគន្ធ បានមានប្រសាសន៍ថា សមា-គម និងសហគមន៍ មិនប្រឆាំងនឹងការសម្រេចនេះទេ។ ប៉ុន្តែសូមឱ្យរដ្ឋាភិបាលសិក្សា ឱ្យបានហ្មត់ចត់ជាងនេះ ដោយសារតែអាងស្ទាក់ទឹកទាំងអស់ នេះមិនត្រឹមតែពុំប៉ះពាល់ដល់វិស័យជលផល និងរបបជលសាស្ត្រប៉ុណ្ណោះទេ។ ប៉ុន្តែវាជាជម្រុកស្រូវរបស់កសិករចំនួន៧០០០គ្រួសារ និងក៏ជាកន្លែងអភិរក្សត្រី ព្រមទាំងជីវសាស្ត្រចម្រុះផ្សេងទៀតផងដែរ។ លោកក៏បញ្ជាក់ថា : "ពួកយើងអត់ប្រឆាំងនឹងការលុបនោះទេ។ តែចាំទីនោះ មានប្រព័ន្ធធារាសាស្ត្រសិន"។ លោកបានឱ្យដឹងដែរថា ទីនោះលិចទឹកនៅរដូវវស្សា កម្ពស់រហូតដល់ទៅ ២ម៉ែត្រ។ តែទំនប់អាងភាគច្រើន គឺមានកម្ពស់ត្រឹមតែ ១,៣០ម៉ែត្រប៉ុណ្ណោះ។ ដូច្នេះវាមិនប៉ះពាល់ដល់លំហូររបស់ទឹកចូលបឹងទន្លេសាបទេ ហើយមិនតែប៉ុណ្ណោះ ទីនោះក៏ជាតំបន់រក្សាទុកត្រីមេពូជដ៏សំខាន់ ដោយសារតែសហគមន៍ទីនោះ មានការយកចិត្តទុកដាក់ណាស់លើការការពាររាល់បទល្មើសនេសាទផ្សេងៗ លើកលែងតែការនេសាទជាគ្រួសារ ។

ជុំវិញបញ្ហានេះ លោកអ៊ុំ សាមហាក់ បានស្នើសុំឱ្យរដ្ឋាភិបាលកុំឱ្យបំផ្លាញអាងទាំងអស់នោះចោល ដោយសារអាងនោះជាជីវិតរបស់ពួកគាត់។ លោកបញ្ជាក់ថា: "បើបំផ្លាញអាងដូចសម្លាប់ខ្ញុំហើយ"។

បងស្រីជុំ វណ្ណី ជាអ្នកនេសាទមកពីភូមិអូរគន្ធក្រុងស្ទឹងសែន ក៏បានឱ្យដឹងថា គ្រួសារគាត់សព្វថ្ងៃនេះ គឺរស់នៅជាមួយនឹងការនេសាទត្រីពីអាងទឹកទាំងនេះ សម្រាប់ធ្វើត្រីឆ្អើរ ត្រីងៀត យកទៅលក់នៅផ្សារ។ បងស្រីបានបញ្ជាក់ថា: "គ្រួសារខ្ញុំ មានកូន ៨នាក់ អត់មានដីស្រែទេ ប៉ុន្តែបើអត់អាងនេះទៀតយ៉ាប់ហើយ"។

## ប្រវត្តិកកើតអាងនៅតំបន់វាលស្រែប្រាំង

លោកហង់ សុគន្ធ ប្រធានសមាគមអភិវឌ្ឍន៍ស្រែប្រាំងកម្ពុជា បានឱ្យដឹងថា ចលនានៅក្នុងការកែច្នៃធម្មជាតិដើម្បីបង្កបង្កើនផលស្រូវនេះ គឺបានចាប់ផ្តើមដំបូងនៅក្នុងឆ្នាំ២០០៤។

លោកបានបន្តទៀតថា ចលនានេះបានកើតមានឡើងក្រោយដំណើរទស្សនកិច្ចរបស់ប្រមុខរដ្ឋាភិបាលកម្ពុជា ដែលចុះសម្ពោធសមិទ្ធផលមួយនៅក្នុងខេត្តកំពង់ធំ និងបានជំរុញឱ្យកសិករកែច្នៃពូជស្រូវដោយសារតែការធ្វើស្រែឡើងទឹកនៅក្នុងតំបន់នោះមិនសូវទទួលបានផល។

លោកបានឱ្យដឹងថា បណ្តាអាងស្ទាក់ទឹកទាំងអស់នេះ គឺធ្វើនៅលើដីស្រែដែលកសិករគាត់ធ្លាប់បានធ្វើតាំងពីយូរយារ ប៉ុន្តែត្រូវបានបោះបង់ចោលមួយរយៈពេលដោយសារតែសង្គ្រាមស៊ីវិល។ លោកបានឱ្យដឹងថា ផ្ទៃដីស្រែប្រាំងសម្រាប់ប្រភេទពូជស្រូវប្រដេញទឹកនេះតាំងពីសង្គម មានចំនួន ៨០០០០ហិចតា។ ប៉ុន្តែបច្ចុប្បន្ននេះ គឺទើបតែអនុវត្តបានប្រមាណ ២៦០០០ហិចតាប៉ុណ្ណោះ។

March-2010.qxd 6/10/2010 2:51 PM Page 12



# គ្រីស្តបរិស័ទកាតូលិក បរិច្ចាគឈាមដើម្បីជួយដល់អ្នកជំងឺ

**កែវ កញ្ញា**



Photo : Kagha

នៅម៉ោងប្រមាណ ៨ព្រឹក រថយន្តមួយគ្រឿង ដែលមានបិទស្លាកឈ្មោះថា មជ្ឈមណ្ឌលជាតិផ្តល់ឈាម ផ្ទុកដោយបរិក្ខារពេទ្យបានចតនៅពីមុខព្រះវិហារកាតូលិកព្រះកុមារយេស៊ូ ដើម្បីទទួលនូវការបរិច្ចាគឈាមរបស់គ្រីស្តបរិស័ទកាតូលិក នៅព្រះវិហារនេះដែលស្ថិតនៅផ្ទះលេខ៩៨អា ក្រុម៩ ភូមិសន្សំកុសល សង្កាត់បឹងទំពុន រាជធានីភ្នំពេញ។

កម្មវិធីនេះមានការចូលរួមពីសំណាក់គ្រីស្តបរិស័ទប្រមាណ ២០នាក់ ដែលក្នុងនោះ ភាគច្រើនជាយុវជនយុវនារី ហើយ ក៏មានការចូលរួមពីសំណាក់បព្វជិត-ជីតានិងគ្រីស្តបរិស័ទផងដែរដោយបានធ្វើឡើង កាលពីថ្ងៃទី៧ ខែកុម្ភៈ កន្លងទៅនេះ។

កំពុងសម្រាកនៅលើគ្រែនៅក្នុងឡាននៃមជ្ឈមណ្ឌលជាតិផ្តល់ឈាម អេង សានី អាយុ២៨ នូវីស នៃក្រុមគ្រួសារបងស្រីឧបការគុណនៅកម្ពុជា មានប្រសាសន៍ថា : "ខ្ញុំមានចិត្តសប្បាយរីករាយណាស់ ដែលបានបរិច្ចាគឈាមដើម្បីជួយដល់អ្នកជំងឺដែលនៅតាមមន្ទីរពេទ្យផ្សេងៗ។" នូវីសរូបនេះ បានឱ្យដឹងដែរថា នេះជាលើកទី៣ហើយដែលរូបគាត់បានធ្វើការបរិច្ចាគឈាម។

កញ្ញាប៉ោឡា មោជរ អ្នកគ្រប់គ្រងគណៈកម្មាការសុខភាពព្រះសហគមន៍កាតូលិកប្រចាំភូមិភាគភ្នំពេញ ក៏បានមានប្រសាសន៍ថា ការបង្កើតកម្មវិធីនេះគឺដើម្បីជួយទៅដល់អ្នកជំងឺទូទៅដែលត្រូវការសង្គ្រោះបន្ទាន់ ដោយគ្រាន់តែអ្នកជំងឺ ដែលមកពីព្រះសហគមន៍ប៉ុណ្ណោះទេ។

តាមរយៈបទពិសោធន៍កន្លងមក កញ្ញាប៉ោឡា បានឱ្យដឹងថា : "កាលពីមុនយើងពិបាករកអ្នកបរិច្ចាគឈាម និងកង្វះឈាមនៅតាមមន្ទីរពេទ្យ។តែឥឡូវនេះគឺវាស្រួលជាង។យើងមានទំនាក់ទំនងជាមួយមជ្ឈមណ្ឌលជាតិផ្តល់ឈាម ហើយគ្រីស្តបរិស័ទក៏មកបរិច្ចាគឈាមក្នុងព្រះវិហារច្រើន"។

លោកហុក គីមចេង ជាអនុប្រធានមជ្ឈមណ្ឌលជាតិផ្តល់ឈាម ក៏បានមានប្រសាសន៍ថា កង្វះខាតឈាមនៅក្នុងមន្ទីរពេទ្យនៅតែមានការកើនឡើង ដោយសារមានអ្នកបរិច្ចាកឈាមស្ម័គ្រចិត្តតែ៣០%ប៉ុណ្ណោះ នៃតម្រូវការឈាមសរុប។

ចំណែកកញ្ញាប៉ោឡា បានបញ្ជាក់ទៀតថា អ្នកជំងឺ ដែលស្នាក់នៅមន្ទីរពេទ្យគឺសុទ្ធសឹងជាបងប្អូនរបស់យើង ដែលត្រូវការការសង្គ្រោះ ពីយើងរាល់គ្នា។ ដូច្នេះគាត់បានសំណូមដល់គ្រីស្តបរិស័ទទាំងអស់ សូមកុំមានការភ័យខ្លាចក្នុងការបរិច្ចាគឈាម ព្រោះការបរិច្ចាគនេះមិនប៉ះពាល់សុខភាពឡើយ។

នេះគឺជាលើកទី៧ ដែលគ្រីស្តបរិស័ទបឹងទំពុនបានផ្តល់ការបរិច្ចាគឈាម។ ហើយក្នុងមួយលើកៗមានគ្រីស្តបរិស័ទចូលរួមពី២០ ទៅ៣០នាក់។

## ក្រុមស្ម័គ្រចិត្តបារាំងកសាងផ្ទះចំនួន២ខ្នង នៅព្រះសហគមន៍ខេត្តក្រចេះ និងក្តុលលើ

ក្រុមស្ម័គ្រចិត្តបារាំងចំនួន ៩នាក់ បានមកដល់ប្រទេសកម្ពុជា កាលពីថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១០ដើម្បីកសាងផ្ទះដល់បងប្អូនក្រីក្រដែលជាការឧបត្ថម្ភពីអង្គការ គូជឺពូស៍ អ៊ុយម៉ានីទែរ៍។

លោកស្រី ដូមីនីក៍ ដឺ ពីរៃ អ្នកដឹកនាំក្រុមនេះបានមានប្រសាសន៍ថា យើងមកទីនេះដើម្បីសង់ផ្ទះដល់បងប្អូនក្រីក្រ : មួយខ្នងនៅក្នុងព្រះសហគមន៍ក្រចេះ នាខេត្តក្រចេះ និងមួយខ្នងទៀតនៅព្រះសហគមន៍ក្តុលលើ ក្នុងស្រុកក្រូចឆ្មារ នាខេត្តកំពង់ចាម។ អ្នកស្រីក៏បន្តថា កិច្ចការនេះ គឺយើងមានគោលបំណងសំខាន់មួយរបស់ក្រុម គឺដើម្បីឱ្យមាន ទំនាក់ទំនងយ៉ាងជិតស្និត ជាមួយបងប្អូនខ្មែរ និងបារាំងក្នុងការរស់នៅជាមួយគ្នា ស្គាល់គ្នា និងនិយាយជាមួយគ្នា។ទោះបីយើងពុំមានភាសាដូចគ្នាក៏ដោយ ប៉ុន្តែយើងមានអារម្មណ៍យល់គ្នា។ ហើយនេះក៏ជាសំណូមពរពីលោកបូជាចារ្យ អ៊ីវ៉ាន់ កំប៉ាញ៉ា ដែលលោកជាអ្នកគ្រប់គ្រងផ្ទាល់ ចំពោះព្រះសហគមន៍ទាំងពីរនេះផងដែរ។

នេះជាលើកទី៤ហើយ ដែលសកម្មភាពរបស់គូជឺពូស៍ អ៊ុយម៉ានីទែរ៍ បានជួយកសាងផ្ទះដល់បងប្អូនក្រីក្រនៅទីនេះ។

អ្នកស្រី ដូមីនីក៍ ដឺ ពីរៃ មានប្រសាសន៍បន្ថែមថា ទោះបីការងារមានការនឿយហត់យ៉ាងណាក្តី ក៏យើងនៅមានអំណរសប្បាយដែរ។ ការងារនេះថ្មីសម្រាប់ក្រុមថ្មីរបស់យើង។



Photo : Fr. Ivan

**ហ៊ូ សុខធារី**

March-2010.qxd 6/10/2010 2:51 PM Page 13



# សិក្ខាសាលាអ្នកណែនាំអប់រំជំនឿអំពីពិធីផ្សេងៗ

សិក្ខាកាមប្រមាណជាង៩០នាក់ បានចូលរួមក្នុងអង្គសិក្ខាសាលាមួយ ស្តីអំពីការប្រារព្ធពិធីផ្សេងៗ ក្នុងដំណាក់កាលនៃការអប់រំជំនឿសម្រាប់មនុស្សពេញវ័យក្នុងព្រះសហគមន៍កាតូលិកនៅកម្ពុជា។

នៅអង្គសិក្ខាសាលានេះ មានការចូលរួមពីអ្នកណែនាំអប់រំជំនឿទាំងបីភូមិភាគនៅទូទាំងប្រទេស ដែលមានរយៈពេល ៣ថ្ងៃ ចាប់ពីថ្ងៃទី៣-៥ កុម្ភៈ ២០១០ កន្លងទៅនេះ នៅព្រះសហគមន៍កាតូលិកបាត់ដំបង ខេត្តបាត់ដំបង។

លោកគ្រូដួង សាវង្ស អ្នកណែនាំក្នុងអង្គសិក្ខា-សាលា មកពីមណ្ឌលវប្បធម៌កាតូលិកកម្ពុជា បានមានប្រសាសន៍ដែរថា គោលដៅរបស់សិក្ខាសាលាផ្តោតសំខាន់អំពីការធ្វើពីធីផ្សេងៗ ដើម្បីទទួលបងប្អូន ដែលចូលមកស្វែងយល់ពីព្រះជាម្ចាស់នៅក្នុងដំណាក់កាលផ្សេងៗនៃការអប់រំជំនឿ។

លោកគ្រូ សាវង្ស បានឱ្យដឹងដែរថា ការចូលរួមក្នុងសិក្ខាសាលានេះ គឺឱ្យអ្នកណែនាំអប់រំជំនឿទាំងអស់ចូលរួម ចែកចាយបទពិសោធន៍ផ្ទាល់ខ្លួន ដែលមាននៅកន្លែងដែលពួកគាត់ត្រូវបានបង្រៀន។

សិក្ខាកាមចូលរួមដែលជាអ្នកណែនាំអប់រំជំនឿម្នាក់ៗ បានចែកចាយនូវបទពិសោធន៍របស់ខ្លួនក្នុងការធ្វើពិធីនីមួយៗ នៅតាមព្រះសហគមន៍ពួកគាត់ ដូចជាពិធីសុំចូលព្រះសហគមន៍ ពិធីដេញមារ ឬពិធីជាច្រើនទៀត ដែលជាជំនួយដល់បងប្អូនពេញវ័យក្នុងការស្គាល់ព្រះជាម្ចាស់កាន់តែច្បាស់ឡើង។

**ភិរុណា**



Photo : L. Sovanna

**សមាជិកចូលរួមក្នុងអង្គសិក្ខាសាលាដែលមានលោកបូជាចារ្យ បងប្រុស បងស្រី គ្រូអប់រំជំនឿថតរូបជាអនុស្សាវរីយ៍រួមគ្នាយ៉ាងរីករាយ**

## សម្ពោធព្រះវិហារសន្តយ៉ូសែប (ផ្សារតូច)



Photo : Tra

កាលថ្ងៃទី០៦ ខែកុម្ភៈ កន្លងទៅនេះ ព្រះវិហារ សន្តយ៉ូសែប (ផ្សារតូច) ដែលទើបតែជួសជុលរួច ត្រូវបានសម្ពោធឱ្យប្រើវិញ។ ការជួសជុលព្រះវិហារគឺបានចំណាយពេលជាង ១ ឆ្នាំ និងថវិកាជិត ១០០០០០ដុល្លារ ដែលបានឧបត្ថមពីក្រុមគ្រួសារសាសនទូតក្រៅប្រទេសក្រុងប៉ារីស និងគ្រីស្តបរិស័ទព្រះសហគមន៍។

លោកស្រីភួង លីម៉ា និងលោកស្រីង៉ុបស៊ីង គឺជាគ្រីស្តបរិស័ទ និយាយក្នុងន័យស្រដៀងគ្នាថាសំណង់នេះពិតជាធ្វើឱ្យយើងមានអារម្មណ៍សប្បាយរីករាយមែនទែន ពីព្រោះបានឃើញព្រះសហគមន៍យើងមានការរីកចម្រើន។

សូមបញ្ជាក់ថា ព្រះវិហារសន្តយ៉ូសែបនេះបានកសាងដំបូងតាំងពីឆ្នាំ១៩១២ មកម្លេះ។

**នូ អដ្ឋវិចិត្រា**

# គ្រីស្តបរិស័ទរួមគ្នាបញ្ចៀសយុវជនពីអំពើអសីលធម៌

**យឹម ម៉ារី**

នៅថ្ងៃទី១៣ ខែកុម្ភៈ ក្រុមគ្រីស្តបរិស័ទនិកាយប្រូតេស្តង់ បានរៀបចំនូវកម្មវិធីប្រគុំតន្ត្រីមួយដែលមានយុវជនយុវនារី ចូលរួមប្រមាណជាង ២០០០ នាក់ ដែលភាគច្រើនជាគ្រីស្តបរិស័ទនៅក្នុងឱកាសបុណ្យនៃសេចក្តីស្រលាញ់ ដោយផ្តោតលើប្រធានបទ "ស្នេហ៍អមតៈ ស្ម័គ្ររង់ចាំ" ដែលធ្វើឡើងនៅកោះពេជ្រ រាជធានីភ្នំពេញ។

អ្នកស្រីសាមឿន អ៊ីនតាល់ នាយិកានៃស្ថានីយ៍វិទ្យុគ្រួសារ និងជាអ្នកដឹកនាំកម្មវិធី មានប្រសាសន៍កម្មវិធីនេះ គឺចង់ឱ្យយុវជនយល់ដឹងបានច្បាស់ អំពីសេចក្តីស្រលាញ់ពិតប្រាកដ ដោយមិនធ្វើអំពើអ-សីលធម៌ផ្សេងៗ។ អ្នកស្រីបានឱ្យដឹងទៀតថា យុវ-ជនភាគច្រើន បានយកពេលវេលា ដើម្បីដើរលេងគេចសាលាមិនចូលរៀន ហើយពេលខ្លះពួកគេផឹកស្រា រហូតឈានទៅដល់ការធ្វើអំពើខុសប្រពៃណីនៅមុនពេលរៀបការក៏មានដែរ។

កម្មវិធីនេះបានរៀបចំអស់រយៈពេល៣ខែដែលក្នុងនោះ មានទាំងការធ្វើយុទ្ធនាការផ្សេងៗ តាមរយៈវិទ្យុ និងមានការចូលរួមពីមណ្ឌលផ្សព្វផ្សាយព័ត៌មានកាតូលិកផងដែរ។ ក្នុងនោះ ក៏មានបង្កើតល្ខោនខ្លីសម្រាប់ចាក់ផ្សាយ និងមានកម្មវិធី ផ្សាយផ្ទាល់តាមបណ្តាស្ថានីយវិទ្យុផ្សេងៗក្នុងប្រទេស។

សម្រាប់គម្រោងនាឆ្នាំក្រោយ អ្នកស្រីសាមឿនបានឱ្យដឹងដែរថា អ្នកស្រីនឹងមានគម្រោង ក្នុងការបង្កើតជាអង្គសិក្ខាសាលា បោះពុម្ពខិតបណ្ណផ្សព្វផ្សាយ និងនិពន្ធចម្រៀងដើម្បីដាស់តឿនយុវជនយុវនារីឱ្យយល់ដឹងអំពីទង្វើណាដែលគួរប្រព្រឹត្តដើម្បីធ្វើខ្លួនជាយុវជនល្អសម្រាប់សង្គមជាតិ។



Photo : Mary

**យុវវ័យគួរតែស្វែងយល់អំពីក្តីស្រឡាញ់ពិតប្រាកដ**

March-2010.qxd 6/10/2010 2:52 PM Page 14



# ទិដ្ឋភាព និងសកម្មភាពនៅព្រះសហគមន៍កាតូលិកភូមិថ្មី

**លី សុវណ្ណា**

*ទិដ្ឋភាព និងសកម្មភាពគ្រីស្តបរិស័ទ បម្រើសង្គម និងការផ្សព្វផ្សាយដំណឹងល្អរបស់ព្រះសហគមន៍កាតូលិកភូមិថ្មីនៅភូមិភាគកំពង់ចាម ។*



ការសាងសង់សាលាមត្តេយ្យថ្មីសម្រាប់អប់រំកុមារនៅក្នុងភូមិ



ទេសភាព និងបរិវេណព្រះវិហារនៃព្រះសហគមន៍កាតូលិកភូមិថ្មី ស្ថិតនៅឃុំរំចេក ស្រុកកំពង់សៀម ខេត្តកំពង់ចាម



កុមារាកុមារីដែលជាកូនៗរបស់ប្រជាជនក្នុងភូមិ ចូលរៀនសូត្រនៅសាលាមត្តេយ្យដែលបើកឡើងព្រះសហគមន៍កាតូលិក



ការអប់រំកុមារតូចគឺជាមូលដ្ឋានគ្រឹះអប់រំទៅថ្ងៃក្រោយ និងទទួលបានការយកចិត្តទុកដាក់ខ្លាំងក្លាពីព្រះសហគមន៍កាតូលិក



ការធ្វើអនាម័យដោយកក់សក់ដល់កុមារាកុមារីដែលជាផ្នែកនៃកម្មវិធីដើម្បីសុខភាពល្អរបស់ព្រះសហគមន៍កាតូលិកភូមិថ្មី



លោកបូជាចារ្យ ហ្វ្រង់ស៊្វ័រ ជួបសួរសុខទុក្ខ និងសំណេះសំណាលជាមួយបងប្អូនគ្រីស្តបរិស័ទនៅព្រះសហគមន៍កាតូលិកនៅភូមិរលាក ភូមិភាគកំពង់ចាម។

## បទយកការណ៍ព្រះសហគមន៍កាតូលិក

# ទស្សនកិច្ចរបស់អ្នកម្ដាយធំនៃក្រុមគ្រួសារសាលេស៊ាន

**កែវ កញ្ញា**

យុវតី និងស្ត្រីៗប្រមាណជា២០០នាក់ អតីតកូនសិស្សចាស់គ្រប់ជំនាន់របស់សាលាដុនបូស្កូផ្នែកនារី បានមកជួបជុំគ្នាដើម្បីទទួលអ្នកម្ដាយអ៊ីវ៉ុន នៃក្រុមគ្រួសារសាលេស៊ានដុនបូស្កូ និងរួមគ្នា អង្គាសប្រាក់ជួយប្រជាជនហៃទី។ កម្មវិធីនេះ បានធ្វើឡើងនៅដុនបូស្កូទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ថ្ងៃទី២២ កុម្ភៈ ឆ្នាំ២០១០ កន្លងទៅ។

មានប្រសាសន៍ជាភាសាអ៊ីតាលី អ្នកម្ដាយអ៊ីវ៉ុន វ័យ៦៥ឆ្នាំបានលើកឡើងថា: "ខ្ញុំបានឮអ្នករាល់គ្នាចាប់អារម្មណ៍ចំពោះមនុស្សទូទៅ ហើយពេលខ្លះក៏បានបង្រៀនមនុស្សដែលធ្វើការនៅក្នុងស្ថាប័នរដ្ឋផងដែរ។ នេះជាសញ្ញាមួយឆ្លុះបញ្ចាំងពីតម្លៃរបស់កូនសិស្ស ដែលបានរៀនពីដុនបូស្កូ"។

នៅក្នុងប្រទេសកម្ពុជា សមាគមកូនសិស្សចាស់របស់សាលាដុនបូស្កូនារី មានសមាជិក ២០០០នាក់ ដែលកំពុង បម្រើការងារនៅទូទាំងប្រទេសកម្ពុជា ស្ទើរតែគ្រប់វិស័យ ទាំងនៅក្នុងជួររដ្ឋាភិបាល ឯកជន និងអង្គការផ្សេងៗ។

អ្នកម្ដាយបានលើកទឹកចិត្តកូនសិស្សចាស់ទាំងអស់ ឱ្យខិតខំបន្តនូវបេសកកម្មរបស់ខ្លួនក្នុងនាមជាពលរដ្ឋល្អនៅក្នុងសង្គម។ គាត់បានលើកឡើងថា: "ព្រះជាម្ចាស់ស្រលាញ់អ្នក សូមអ្នកចែករំលែកនិងធ្វើជាសាក្សីនៅកន្លែង ដែលអ្នករស់នៅ និងធ្វើការដោយបង្ហាញ នូវសាមគ្គីភាព សេចក្ដីស្រលាញ់ និងភាពរីករាយទៅដល់មនុស្សទាំងឡាយ"។

នេះជាដំណើរទស្សនកិច្ចលើកទីមួយ របស់អ្នកម្ដាយអ៊ីវ៉ុន ជនជាតិបារាំង មកដល់កម្ពុជា បន្ទាប់ពីការជ្រើសតាំងជាអ្នកម្ដាយធំនៅឆ្នាំ២០០៨។

យុវតីជេត មុនីនិត អាយុ២២ឆ្នាំ ប្រធានសិស្សចាស់នៅសាលាដុនបូស្កូផ្នែកលេខាធិការ និងកុំព្យូទ័រ បាននិយាយដែរថា នាងសប្បាយរីករាយណាស់ ដែលអ្នកម្ដាយបានធ្វើដំណើរពីប្រទេសអ៊ីតាលីមកជួបយើងទាំងអស់គ្នា។ អ្នកម្ដាយក៏ផ្ដល់នូវដំបូន្មានល្អដល់យើងរាល់ៗគ្នា ដែលអាចយកទៅអនុវត្តក្នុងជីវិតតទៅមុខទៀត។

ក្រោយមតិផ្ដាំផ្ញើអំពីអ្នកម្ដាយ សិស្សចាស់ទាំងអស់បានធ្វើវិភាគទានថវិកា ដើម្បីចូលរួមរំលែកនូវទុក្ខលំបាករបស់គ្រួសារសាលេស៊ានហៃទីផងដែរ។

កញ្ញាគីម ហេង អាយុ២៤ឆ្នាំ ជាសិស្សចាស់នៃសាលាដុនបូស្កូផ្នែកលេខាធិការិនីបានឱ្យដឹងថា ការចេះចែករំលែកគឺជាអ្វីដែលសំខាន់ណាស់សម្រាប់យើងដើម្បីជួយដល់អ្នកដទៃ ដែលខ្វះខាត។ កញ្ញាបានប្រាប់ថា: "ប៉ុណ្ណឹងមិនទាន់គ្រប់គ្រាន់ទេ ព្រោះប្រទេសហៃទីទទួលរងគ្រោះធំ។ ប៉ុន្តែប្រសិនយើងមានម្នាក់បន្តិចៗនោះ ដប់នាក់ វាក៏អាចជាចំណែកដ៏ធំ ទោះបីមិនបានមួយភាគច្រើន គឺវាបានខ្លះដែរដែលអាចជួយសម្រាលទុក្ខពួកគេ។"

ថវិកាដែលទទួលបានពីការចូលវិភាគទាននោះទទួលមានសរុប ១៨០០០០រៀល និង១៨ ដុល្លារអាមេរិក។ អ្នកម្ដាយអ៊ីវ៉ុន ក៏បានប្រសាសន៍ថា: "ខ្ញុំនឹងនាំ យកថវិកាទាំងនេះទៅប្រទេសហៃទី។ នេះជាការចែករំលែកមួយនៅក្នុងគ្រួសារយើង។"

សូមបញ្ជាក់ថា សាលាបណ្ដុះបណ្ដាលវិជ្ជាជីវៈដុនបូស្កូផ្នែកនារី មានវត្តមាននៅប្រទេសកម្ពុជា ពីឆ្នាំ១៩៩២។ចំណែកឯសមាគមសិស្សចាស់បានត្រូវបង្កើតឡើងនៅឆ្នាំ១៩៩៥ ដែលមានកូនសិស្សអំពីមណ្ឌលចំនួន៣ គឺមានផ្នែកលេខាធិការិនី កុំព្យូទ័រ ផ្នែកវិជ្ជាមេផ្ទះ អក្ខរកម្ម និងកាត់ដេរ។



Photo : K. Kagha

# ជីវិតខ្ញុំ

## សុខណា: “ព្រះសហគមន៍នាំឱ្យស្រឡាញ់ជីវិតជាបូជាចារ្យ”

**តន**


Photo : Ros

នៅអាយុ ២២ឆ្នាំ លោកសុខណា បានចូលរៀនក្នុងទេវវិទ្យាល័យ ដើម្បីសិក្សាស្វែងយល់អំពីជីវិតជាអ្នកបួសតាមបែបកាតូលិក ។ លោកគឺជាកូនពៅនៅក្នុងក្រុមគ្រួសារជំនួញមួយដែលមានសញ្ជាតិជាវៀតណាមមានដើមកំណើត នៅប្រទេសកម្ពុជា ស្ថិតនៅភូមិលូ សង្កាត់ ស្វាយប៉ាក ខណ្ឌ ឫស្សីកែវ រាជធានី ភ្នំពេញ និងមានបងប្អូនបង្កើត ៥នាក់ ក្នុងនោះ មានតែលោកប៉ុណ្ណោះ ដែលជាកូនប្រុសក្នុងគ្រួសារ ។ លោកបានធ្វើពិធីជ្រមុជទឹកឆ្នាំ១៩៨០ ។

នៅឆ្នាំ១៩៨៨ លោកបានចូលសិក្សាភាសាខ្មែរ នាឆ្នាំ១៩៩២ លោកបានសម្រេចចិត្តបោះបង់ចោលការសិក្សា ដើម្បីជួយធ្វើការងាររកម្រៃផ្គត់ផ្គង់ជីវភាពគ្រួសារ ។

ឆ្នាំ១៩៩៨ ស្វាយប៉ាក ចាប់ផ្តើមកកើតមានព្រះវិហារដែលមានលោកបូជាចារ្យទៅថ្វាយអភិបូជាពីរដង ក្នុងមួយខែ ។ ពីមុនលោក និងក្រុមគ្រួសារមិនដែលអាក់ខានក្នុងការចូលវិហារទេ ។ លុះគ្មានអភិបូជានៅក្បែរផ្ទះទេ លោកក៏បានធ្វើដំណើរទៅចូលនៅព្រះវិហារសន្តយ៉ូសែប ។

សុខណាបាននិយាយថា : ”ការយកចិត្តទុកដាក់ និងសេចក្តីស្រលាញ់ដែលបងប្រុសវិន័យ និងបងស្រីស៊ុណា ព្រមនិងលោកបូជាចារ្យចំពោះបងប្អូននៅទីនោះ បានជំរុញឱ្យរូបខ្ញុំកើតចិត្តថ្វាយខ្លួន ទៅបម្រើព្រះជាម្ចាស់តាមរយៈជាបូជាចារ្យ” ។

លោកបន្តយ៉ាងនេះថា : ”ខ្ញុំពិតជាមានសំណាងណាស់ដែលមានអ្នកម្តាយជួយអធិដ្ឋានសម្រាប់រូបខ្ញុំជាប្រចាំក្នុងការថ្វាយខ្លួនបម្រើព្រះយេស៊ូគ្រីស្ត” ។

អ្វីដែលក្រុមគ្រួសាររបស់លោកបានណែនាំរូបលោកអំពីជំនឿនោះ គឺការអធិដ្ឋានរៀងរាល់ម៉ោង ៤ កន្លះទៀបភ្លឺ ។ លោកពោលដូច្នេះថា : ”កាលខ្លួននៅក្មេងមិនយល់ពីអត្ថន័យនៃការអធិដ្ឋាន ។ ពេលខ្លះ រូបខ្ញុំក៏មានការធុញថប់ តែពេលនេះរូបខ្ញុំ យល់ជាក់ច្បាស់ថា មានតែការអធិដ្ឋានទៅកាន់ព្រះបិតាប៉ុណ្ណោះ ដែលអាចដឹកនាំជីវិតប្រចាំរបស់ខ្លួនឱ្យរស់ក្នុងជំនឿដែលមានជីវិតអស់កល្បជានិច្ច” ។

សព្វថ្ងៃ សុខណា កំពុងស្នាក់នៅទេវវិទ្យាល័យសន្តយ៉ូហានម៉ារីវីយ៉ាណេ ហើយលោកកំពុងសិក្សាផ្នែកទស្សនវិជ្ជា នៅសកលវិទ្យាល័យភូមិន្ទភ្នំពេញ ឆ្នាំទី៣ និងសិក្សាស្វែងយល់អំពីជីវិតជា អ្នកបម្រើការរស់នៅជាសហគមន៍ និងជីវិតខាងវិញ្ញាណ ។

រាល់ចុងសប្តាហ៍ លោកសុខណាក៏ទៅបម្រើព្រះសហគមន៍វត្តចំប៉ា ។ លោកពោលថា ការងារបម្រើព្រះសហគមន៍ គឺបានជំរុញឱ្យលោកកាន់តែមានក្តីស្រលាញ់ចំពោះជីវិតជាបូជាចារ្យដោយចែករំលែកនូវក្តីស្រលាញ់ដែលខ្លួនមានចំពោះបងប្អូនដែលមិនត្រឹមតែជាជំនឿ តែជាសក្ខីភាព និងអំណរសប្បាយដែលព្រះជាម្ចាស់ប្រទានឱ្យលោក និងបងប្អូន ។

## ប្រតិទិនអភិបូជា

- **ភាសាខ្មែរ** : ព្រះវិហារសន្តយ៉ូសែបភ្នំពេញ (០១២ ៧៨២ ២៤១) ថ្ងៃច័ន្ទ-សៅរ៍ : ព្រឹកម៉ោង៦។ ថ្ងៃអាទិត្យ : ម៉ោង ៨ព្រឹក និងម៉ោង៤រសៀល។
  -កំពង់សោម (០១៦ ៨៤០ ៥៤០) ថ្ងៃច័ន្ទ ថ្ងៃពុធ និងថ្ងៃសុក្រ : ល្ងាចម៉ោង៥។ ថ្ងៃអង្គារ ថ្ងៃព្រហស្បតិ៍ និងថ្ងៃសៅរ៍ : ព្រឹកម៉ោង៦។ ថ្ងៃអាទិត្យ : ម៉ោង ៨ព្រឹក។
  -សៀមរាប (០៦៣ ៩៦៥ ២៨០) ថ្ងៃអាទិត្យ : ម៉ោង៧:៣០ព្រឹក។ ថ្ងៃច័ន្ទ-ថ្ងៃព្រហស្បតិ៍ : ព្រឹក ៦:៣០ម៉ោង។ ថ្ងៃសុក្រ : ម៉ោង ៦:៣០ល្ងាច។
  -បាត់ដំបង (ពេទ្យយាយជី) ថ្ងៃអាទិត្យ : ម៉ោង ៨:០០ព្រឹក។ ថ្ងៃច័ន្ទ : ល្ងាច៦:០០។ ថ្ងៃអង្គារ-សុក្រ : ម៉ោង៦:១៥ ព្រឹក។
- **Français** : 1er et 3ème Samedi du mois à 5:30pm ; 2ème et 4ème Dimanche du mois à 11:00am; à l'église de St. Joseph, #1788B, RN5, PP.
- **English** : - Phnom Penh : Sunday at 10: 00 am; at St. Joseph Church (#1788B, NR5, PP); Saturday at 5: 00 pm, at World Vision Cambodia (#2 St 71, PP); - Sihaknouk Ville : Sunday at 5:00 pm; # Catholic Church St.12 13 Mattapheap; H/P: 016 840 540 (Fr. Werachai); - Siem Reap : Saturday at 6:30 pm; #Catholic Church, No 027 East River Side Street. - Battambang : Saturday: at 6:00 pm at Battamabang Church (Pet Yeaychi), Rumchek 1, Rattanak, H/P: 012 911 147 (Fr. Totet).

March-2010.qxd 6/10/2010 2:52 PM Page 17





Photo : Sanmao

# គំនូរទំនើបជាគំនូរច្នៃប្រឌិត

**ខាន់ ភីរម្យ**

លោកលាង ស៊ីកន ជាវិចិត្រករខ្មែរមួយរូប បានមានប្រសាសន៍ថា គំនូរទំនើបគឺជាប្រភេទគំនូរដែលវិចិត្រករគូរប្រកបដោយគំនិតច្នៃប្រឌិតដែលកើតចេញពីចិត្ត ហើយនិងវិញ្ញាណរបស់វិចិត្រករផ្ទាល់តែម្តង។តែវាបង្កប់នូវការអប់រំ និងព័ត៌មានឱ្យដល់អ្នកទស្សនាទាំងឡាយ ដែលបានឃើញនូវរាល់ស្នាដៃគំនូរទាំងនេះ។

លោកក៏បានបន្តទៀតថា រហូតមកដល់ពេលនេះ គំនូរមានច្រើនប្រភេទ គឺតាំងពីគំនូរស្រមោល គំនូរកាត់ គំនូរផុស គំនូរពីកាសូរនិងគំនូរអរូបិយជាដើម-ល-។ ប៉ុន្តែរាល់ស្នាដៃទាំងអស់នោះ គឺបែងចែកជាពីរប្រភេទធំៗ: គំនូរបែបទំនើប និងគំនូរបែបបុរាណ។ គំនូរដែលគេហៅថាប្រភេទ គំនូរបុរាណនោះ គឺជាប្រភេទគំនូរដែលកើតពីវិចិត្រករគូរចេញ ឬយកលំនាំពីស្នាដៃគំនូរចាស់ៗ និងមានរូបភាពច្បាស់លាស់។ ប៉ុន្តែសម្រាប់គំនូរ ប្រភេទបែបទំនើបវិញ គឺជាស្នាដៃដែលកើតចេញអំពីគំនិតច្នៃប្រឌិតព្រមទាំងមានបង្កប់ភាសា ឬក៏អត្ថន័យ និងការព្យាករណ៍ទៅថ្ងៃមុខផងដែរ។

ចំពោះស្នាដៃគំនូរទំនើបនេះ គេអាចគូរគ្រប់ទិដ្ឋភាព ដែលកំពុងកើតមាន នៅក្នុងពេលអតីតកាល បច្ចុប្បន្ន ឬអនាគតដោយបង្កប់នូវព័ត៌មាន និងការបកស្រាយ ខុសៗគ្នា។ ក្រៅពីនោះ គេអាចគូសវាសនូវគំនិតស្រមើស្រមៃ អំពីរឿងរ៉ាវ ដែលអាចកើតមាននៅក្នុងពេលអនាគតផងដែរ។

លោកស៊ីកនបញ្ជាក់ដែរថា: "ជាក់ស្តែងសម្រាប់ខ្ញុំស្នាដៃដែលគេចាត់ទុកថាជាគំនូរបែបទំនើបនោះ ជាការយកសំរាមមក កែច្នៃជាផ្ទាំងគំនូរផុសដើម្បីអប់រំសាធារណជនឱ្យយល់ដឹងអំពីបញ្ហាសំរាម និងបរិស្ថាននៅក្នុងប្រទេសកម្ពុជា"។

ក្រៅពីស្នាដៃគំនូរ ផុសដោយកើតចេញពីការកែច្នៃដោយយកកម្ទេចកំទី ដែលគេបោះចោល មកកាត់ដេរ និងទឹកថ្នាំ ហើយនោះ អ្នកសិល្បៈករផ្សេងៗទៀត ដែលពួកគេគូសនូវគំនូរផ្សេងៗ ដែលជួនកាល អ្នកខ្លះមើលអត់យល់ ឬក៏បង្កប់នូវភាសា និងសញ្ញាផ្សេងៗ ដែលវានាំឱ្យអ្នកទស្សនាបកស្រាយចេញជាអត្ថន័យខុសៗគ្នា ក៏គេអាចចាត់ទុកថាជាស្នាដៃសិល្បៈគំនូរបែបទំនើបនេះផងដែរ។

លោកស៊ីកនបានបញ្ជាក់ដែរថា : "គំនូរទំនើប គឺជាស្នាដៃគំនូរដែលថ្មីប្លែក។ តែវាមានអត្ថន័យ ព្រមទាំងខ្លឹមសារអាចទាក់ទាញចំណាប់អារម្មណ៍ និងផ្តល់នូវព័ត៌មាន និងការស្វែងយល់ខុសៗគ្នា ទោះសិល្បៈករគូសអំពីអាកាសធាតុ គ្រោះធម្មជាតិ ឬអ្វីក៏ដោយនោះហើយ ជាស្នាដៃគំនូរទំនើប"។

## សៀវភៅ

### រង្វាស់រង្វាល់



នេះជាប្រភេទសៀវភៅឯកសារដែល និយាយពីទម្ងន់ ចំនួន ប្រវែង ជម្រៅ កម្ពស់ ទំហំនិងចំណុះ... នៅក្នុងសង្គមខ្មែរ តាំងពីសម័យបុរាណរហូតដល់បច្ចុប្បន្ន។

នាជីវភាពប្រចាំថ្ងៃ ជនជាតិខ្មែរច្រើនប្រើរង្វាស់រង្វាល់តាម បែបប្រពៃណី ដូចជាខ្នាតទាក់ទងនឹងទំហំ ឬប្រវែងដែលគេតែងប្រៀបធៀបមកនឹងខ្លួនមនុស្ស ពិសេសអវៈយវៈ ដូចជាប៉ុនកដៃ ប៉ុនភ្លៅ ឬ១ហត្ថ ជាដើម។ ជួនកាលគេយកវត្ថុប្រៀបទៅនឹងផ្លែឈើ ឬរុក្ខជាតិ ដូចជាប៉ុនដូងទុំ ប៉ុនគល់ត្នោត ឬកម្ពស់ចុងដូង...។

ឯរង្វាស់រង្វាល់ខ្លះទៀត ខ្មែរយើងមានប្រើតាមរបៀបបរទេសផងដែរ ដូចជាម៉ែត្រ គីឡូម៉ែត្រ គីឡូក្រាម អ៊ីងឬផោន...។ ក្រៅពីនេះ អ្នកអាននឹងស្គាល់អំពីរង្វាស់រង្វាល់ផ្សេងៗ ជាច្រើនទៀត ដែលមនុស្សចាស់ៗ នៅតាមតំបន់នីមួយៗប្រើផងដែរ ដូចជាធូបមួយខ្សុក កំណាត់មួយត្បូង ឬឈើមួយទោម...។

រង្វាស់រង្វាល់ និពន្ធដោយ ជា ណារិន។ សៀវភៅនេះមានលក់ក្នុងតម្លៃ ២០០០០រៀល។

### ឆ្ងាយហួសពីជើងមេឃ



រឿងសរសេរដោយអ្នកស្រីឡូរ៉ង់ ពិក។ អ្នកស្រីជាជនជាតិបារាំងដែលបានរៀបការជាមួយនិងបុរសខ្មែរម្នាក់ហើយមករស់នៅក្នុងរបបខ្មែរក្រហមអស់រយៈពេល៥ឆ្នាំ។

ដោយសារតែក្តីស្រលាញ់ និងចង់គាំទ្រប្តី អ្នកស្រី និងកូនស្រីពីរនាក់បានចាកចេញពីប្រទេសបារាំង ដើម្បីមករួមចំណែកប្រយុទ្ធ"កសាងសង្គមថ្មីមួយ"នៅកម្ពុជា។ អ្នកស្រីក៏ធ្លាប់បានស្រមៃថា ខ្លួននឹងបានរស់នៅក្នុងសង្គមមួយស្មើភាព និងយុត្តិធម៌។ ប៉ុន្តែតថភាពពិតបានបំផ្លាញចោលនូវការស្រមើស្រមៃទាំងនោះបន្តិចម្តងៗ ដោយទុកជំនួសមកវិញនូវភាពភ័យខ្លាច តក់ស្លុត និងការអត់ឃ្លាន... ដែលរកទីបំផុតគ្មាន។ ដើម្បីកូនស្រីទាំងពីរ អ្នកស្រីបានទ្រាំនឹងការរស់នៅដ៏សែនលំបាក ហើយជម្នះគ្រប់ឧបសគ្គដោយអស់សង្ឃឹមផង និងសង្ឃឹមផង។

ឆ្ងាយហួសពីជើងមេឃ ជារឿងប្រវត្តិសាស្ត្ររបបខ្មែរក្រហម។ រឿងនេះបង្ហាញពីផ្នត់គំនិត ការដឹកនាំការបោសសំអាតខ្មាំង និងមោទនភាពហួសហេតុរបស់ខ្មែរក្រហម។ រឿងនេះប្រែជាភាសាខ្មែរដោយឯកឧត្តមខៀវ កាញារីទ្ធ។

**ហេង ដារី**

March-2010.qxd 6/10/2010 2:52 PM Page 18

## ប្រវត្តិសាស្ត្រ

# ហៃទី : "គ្រោះរញ្ជួយដីវេទនាគ្មានអ្វីផ្ទឹម"

**ជាត សំភី**

ប្រជាជនឥណ្ឌាស្បែកក្រហម ជាអ្នករស់នៅលើកោះ មុនការមកដល់របស់លោកគ្រីស្តូហ្វ កូឡុំ ជាជនជាតិអេស្ប៉ាញ នៅខែធ្នូ ឆ្នាំ១៤៩២។

ជនជាតិអេស្ប៉ាញរុករកលើកោះ ដើម្បីភាពរុងរឿងរបស់ខ្លួន។ ជនជាតិដើមស្បែកក្រហមដែលពុំព្រមធ្វើការនៅតាមអណ្តូងរ៉ែត្រូវសម្លាប់និងបន្ថយឋានៈមកនៅត្រឹមទាសករ។ ជនជាតិអឺរ៉ុបក៏បាននាំមកនូវជំងឺឆ្លងយ៉ាងសាហាវ។ ការព្យាបាលមិនល្អ កង្វះអាហារូបត្ថម្ភ និងការថយចុះអត្រាកំណើតធ្វើឱ្យជនជាតិដើមស្លាប់យ៉ាងរង្គាល។

បន្តិចម្តងៗ ផ្ទៃដីកោះបានក្លាយជាអាណានិគមបារាំងបន្ទាប់អំពីការដកថយរបស់អេស្ប៉ាញ។ នៅសតវត្សរ៍ទី១៨ តំបន់នេះជាតំបន់រុងរឿងបំផុតនៃអាណានិគមនានារបស់បារាំង ដោយសារតែផលិតកម្មស្ករនិងកាហ្វេ។ ៩០% នៃប្រជាជននៅហៃទីជាទាសករជនជាតិស្បែកខ្មៅ អ្នកទោសដែលត្រូវដោះលែង និងកូនកាត់ស្បែកស និងស្បែកខ្មៅ។

បន្ទាប់ពីការបណ្តេញជនជាតិបារាំង លោកហ្សង់ហ្សាក់ ដេសាលីន ក៏បានប្រកាសខ្លួនជាអធិរាជ និងប្រកាសឯករាជ្យ ដោយដាក់ឈ្មោះប្រទេសថាហៃទី នៅឆ្នាំ១៨០៤។ នៅសតវត្សរ៍ទី១៩ ហៃទីមានអស្ថិរភាពជាខ្លាំង ព្រោះតែប្រទេសក្រីក្រ និងមានមេដឹកនាំតិចតួចប៉ុណ្ណោះដែលយកចិត្តទុកដាក់លើការអភិវឌ្ឍផ្នែកសេដ្ឋកិច្ច។ នាខណៈដែលការកាន់អំណាចមានសភាពផុយស្រួយ ការបះបោរយោធាកើតឡើងមិនឈប់ឈរ ដែលវាបង្កើតឡើងដោយអ្នកឡើងស្នងតំណែង។

នៅសតវត្សរ៍ទី២០ ពីឆ្នាំ១៩១៥-១៩៣៤ ការជំពាក់បំណុលបរទេស និងវិបត្តិនយោបាយ បង្កឱ្យមានការធ្វើអន្តរាគមន៍របស់សហរដ្ឋអាមេរិកដើម្បីលុកលុយគ្រប់គ្រងហៃទី។ អាមេរិកបានធ្វើដូច្នេះក៏ដើម្បីប្រឆាំងដល់ឥទ្ធិពលរបស់ចក្រភពអាឡឺម៉ង់ដែលចេះតែរីកដុះដាលផងដែរ។

បន្ទាប់ពីការចាកចេញរបស់សហរដ្ឋអាមេរិក អស្ថិរភាពនយោបាយបានវិលត្រឡប់មកវិញរវាងក្រុមយោធា និងប្រជាជន ហើយបានបញ្ចប់នៅឆ្នាំ១៩៥៧ ជាពេលនៃការឡើងកាន់អំណាចផ្តាច់ការរបស់ក្រុមត្រកូលឌុយវ៉ាលីយេ ដែលបានគ្រប់គ្រងរហូត ដល់ឆ្នាំ១៩៨៦។ លិទ្ធិផ្តាច់ការរបស់ត្រកូលឌុយវ៉ាលីយេ ជាអ្នកទទួលខុសត្រូវលើឃាតកម្មជាច្រើន និងការសម្លាប់ជនប្រឆាំង។ នៅសម័យនោះមានប្រជាជនហៃទីជាច្រើនបានធ្វើនិរទេសខ្លួន ទៅកាន់អាមេរិក និងកាណាដា។ ត្រកូលឌុយវ៉ាលីយេត្រូវបានផ្តួលរំលំដោយបដិវត្តន៍របស់ប្រជាជន។ ប្រជាធិបតេយ្យត្រូវស្តាបនាឡើងបន្តិចម្តងៗ។

លោកហ្សង់បេត្រង់ អារីស្ទីត បានឈ្នះការបោះឆ្នោតនៅខែធ្នូ ឆ្នាំ១៩៩០។ តែលុះដល់ខែកញ្ញា ឆ្នាំ១៩៩១ រដ្ឋប្រហារដែលដឹកនាំដោយលោករ៉ាអូល សេដ្រាស និងក្រុមយោធា បានបណ្តេញរូបលោក។

នាឆ្នាំ១៩៩៤ លោកអារីស្ទីតត្រូវបានគេស្តាបនាអំណាចឡើងវិញក្រោមរដ្ឋការរបស់លោកប្រធា-នាធិបតីសហរដ្ឋអាមេរិកប៊ីល គ្លីនតុន អំឡុងពេលប្រតិបត្តិការ "ការស្តាបនាអំណាចឡើងវិញ"។

នៅឆ្នាំ២០០៤ លោកអារីស្ទីត ត្រូវបានដួលរលំដោយសារបាតុកម្មរបស់ប្រជាជន និងសំពាធដែលបង្កឡើងដោយសហគមន៍អន្តរជាតិ ព្រោះអាណត្តិរបស់លោកក្រៅពីកំណែទម្រង់យ៉ាងតិចតួចនោះលោកធ្វើភេរវកម្មលើប្រជាជន។

ចាប់ពីឆ្នាំ២០០៦មក គឺជាអាណត្តិរបស់លោករ៉ឺនេ ប្រេវ៉ាល់ ធ្វើជាប្រធានាធិបតី។




Photos : DR



### ហៃទី និងការរញ្ជួយដីមិនធ្លាប់មាន

**រដ្ឋភាគខាងលិចនៃកោះហៃទី។ មានផ្ទៃដី ២៧ ៧៥០ គម២ និង មានប្រជាជន ៩០៣៥៤៣៦នាក់។ រាជធានី ព័រអូប្រាំងស៍។ នៅថ្ងៃទី១២ ខែមករា ឆ្នាំ២០១០ ការរញ្ជួយដីដែលមានកម្លាំង ៧ រិចទ័របានវាយប្រហារលើភាគខាងលិចរបស់ប្រទេសហៃទី ជាពិសេសលើរាជធានីព័រអូប្រាំងស៍។ វាគឺជាការរញ្ជួយដីដ៏សម្បើម និងបង្កសោកនាដកម្មបំផុតនៃប្រវត្តិសាស្ត្រហៃទី ដែលវានាំផលការបាត់បង់សណ្តាប់ធ្នាប់ទាំងស្រុងនៃដំណើរការរបស់រដ្ឋនេះដោយមើលឃើញតាមរយៈការស្រុតចុះនៃអគារសាធារណៈជាច្រើន ដូចជាសាលារៀន មន្ទីរពេទ្យ ព្រះវិហារ ឬវិមានប្រធានាធិបតី... ដែលឱ្យមានការស្លាប់របស់សមាជិករដ្ឋាភិបាលជាច្រើន (រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ សេដ្ឋកិច្ច និងទេសចរណ៍)។**

**យោងតាមទិន្នន័យពីការិយាល័យការពារជនស៊ីវិលហៃទី គុណ្យកាលនៅថ្ងៃទី២៨ ខែមករា ឆ្នាំ២០១០ បានបង្ហាញថា មានប្រជាជនបាត់បង់ជីវិតរហូតដល់ ១៧០០០០នាក់ និងមានប្រជាជន ២៥០០០០នាក់រងរបួស និង ១០០០០០០នាក់ទៀត បានបាត់បង់ទីជម្រក។**

March-2010.qxd 6/10/2010 2:52 PM Page 19

# អធិប្បាយព្រះបន្ទូលថ្ងៃអាទិត្យ



អ្នកនាំសារខែមីនា ២០១០- ដោយលោកគ្រូដួង សាខឿ

**អាទិត្យទី៣ ក្នុងរដូវអប់រំពិសេស (ថ្ងៃ០៧ ខែមីនា ឆ្នាំ២០១០)** *លូកា ១៣,១-៩*

ជនជាតិយូដា ក៏ដូចជនជាតិខ្មែរយើងដែរ តែងគិតថា អ្នករងទុក្ខលំបាកជាអ្នកប្រព្រឹត្តកម្មអាក្រក់ពីមុន ។ ដោយសារគេយល់បែបនេះហើយ ទើបនាំឱ្យគេវិនិច្ឆ័យទុកជាមុន និងរើសអើងចំពោះអ្នករងទុក្ខលំបាកដោយសារអំពើអយុត្តិធមិ ដោយជំងឺ ឬក៏ដោយគ្រោះថ្នាក់ផ្សេងៗ ថាជាអ្នក បាប ឬជាអ្នកដែលបានប្រព្រឹត្តិអំពើអាក្រក់ពីមុនមក...។ ព្រះយេស៊ូពុំសព្វព្រះហឫទ័យនឹងយោបល់បែបនេះទេ ។ ព្រះអង្គក៏មិនវិនិច្ឆ័យអ្នករងទុក្ខលំបាកថា ជាមនុស្សអាក្រក់ដែរ ។ តែអ្វីដ៏សំខាន់គឺព្រះអង្គសូមឱ្យមនុស្សគ្រប់ៗ រូបចាប់អារម្មណ៍ចំពោះសេចក្ដីស្រឡាញ់របស់ព្រះបិតាវិញ ។ ដូច្នេះមនុស្សគ្រប់ៗរូបត្រូវតែផ្ញើជីវិតលើព្រះបិតាដែលសព្វព្រះហឫទ័យ ទុកឱកាសជានិច្ចឱ្យខ្លួនកែប្រែចិត្ត ដូចអ្នកថែចម្ការអង្វរម្ចាស់ខ្លួនឱ្យទុកដើមឧទុម្ពរ ដែលមិនទាន់បង្កើតផលផ្លែដូច្នោះដែរ ។

**-តើព្រះជាម្ចាស់ទុកពេលឱ្យខ្ញុំប្រែចិត្តរឿងអ្វីក្នុងរដូវអប់រំពិសេសនេះ ?**

**ថ្ងៃអាទិត្យទី៤ ក្នុងរដូវអប់រំពិសេស (ថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១០)** *លូកា ១៥,១-៣.១១-១២*

ជនជាតិយូដាគោរពចំពោះព្រះជាម្ចាស់ទុកជាចៅក្រមឬជាចៅកែដ៏តឹងរ៉ឹងម្នាក់ ។ ព្រះយេស៊ូរកឱកាសពន្យល់គេថា ព្រះជាម្ចាស់ជាព្រះបិតាមិនមែនជាចៅក្រមទេ ព្រះអង្គស្រឡាញ់អ្នកបាបហួសពីការស្មាន ។ ក្នុងអត្ថបទនេះ មានតួអង្គបី តែសំខាន់ គឺតួឪពុក ។ កូនពៅជាមនុស្សពុំសូវល្អប៉ុន្មាន? សុំចែកទ្រព្យពីឪពុកហើយយកទៅចាយវាយអស់ទៅ ។ ឯកូនបងមិនឃ្លាតពីឪពុកទេ ។ តែក៏មិនមែនជាមនុស្សល្អដែរ គេមានចិត្តច្រណែន ។ កូនទាំងពីរសុទ្ធតែមានកំហុស ហើយរកតែប្រយោជន៍ផ្ទាល់ខ្លួន តែអ្វីដែលសំខាន់នោះ គឺក្ដីស្រឡាញ់ដ៏លើសលប់របស់ឪពុកចំពោះកូនទាំងពីរនោះវិញ ។ ឪពុកមិនប្រកាន់កូនណាសោះ ហើយទទួលគេដោយចិត្តស្រឡាញ់ទៀតផង ។ តាមពិតតួអង្គឪពុកគឺជានិមិត្តរូបព្រះបិតា ដែលស្រឡាញ់មនុស្សយើងគ្រប់ៗគ្នា ។ ព្រះអង្គមិនប្រកាន់អ្នកបាបទេ តែព្រះអង្គសុំឱ្យយើងប្រែចិត្តដើម្បីទទួលជីវិត ។

**-តើខ្ញុំដូចកូនពៅ ឬកូនបងយ៉ាងណាក្នុងការរស់នៅ ?**

**អាទិត្យទី៥ ក្នុងរដូវអប់រំពិសេស (ថ្ងៃទី២១ ខែមីនា ឆ្នាំ២០១០)** *យ៉ូហាន ៨,១-១១*

តាមវិន័យលោកម៉ូសេអ្នកប្រព្រឹត្តអំពើសហាយស្មន់នឹងត្រូវគេសម្លាប់ដោយគប់នឹងដុំថ្ម ។ជនជាតិយូដារស់នៅតាមប្រពៃណីនេះតាំងពីយូរសតវត្សរ៍មុនសម័យព្រះយេស៊ូ ។ ព្រះយេស៊ូយាងមក ប្រកាសអំពីព្រះហឫទ័យប្រណីសន្ដោសរបស់ព្រះបិតាចំពោះអ្នកបាប ។ មេដឹកនាំសាសនាយូដាក៏ជំទាស់នឹងព្រះអង្គយ៉ាងខ្លាំង ដោយចោទថា ព្រះអង្គប្រមាថព្រះជាម្ចាស់ ឬបំផ្លាញប្រពៃណីដូនតា...។ ពេលគេនាំអ្នកបាបឱ្យព្រះអង្គវិនិច្ឆ័យដើម្បីចាប់កំហុស ។ ព្រះអង្គមិនវិនិច្ឆ័យនាងទេ ហើយព្រះអង្គសូមឱ្យអស់អ្នក ដែលចង់វិនិច្ឆ័យនាងសម្លឹងមើលខ្លួនជាមុនសិនមុនសម្លាប់នាង ។ គ្មាននរណាសម្លាប់នាងទេ ព្រះយេស៊ូក៏មិនដាក់ទោសនាងដែរ ហើយព្រះអង្គអញ្ជើញនាងឱ្យចេញទៅគឺឱ្យចេញពីសេចក្ដីស្លាប់ទៅកាន់ជីវិត ។ អត្ថបទនេះព្រះយេស៊ូផ្ដល់សក្ខីភាពពីព្រះបិតាលើកលែងទោស និងប្រទានជីវិតថ្មីឱ្យយើង ។

**-តើខ្ញុំជឿយ៉ាងពិតប្រាកដថា ខ្ញុំបានទទួលជីវិតអស់កល្បជានិច្ចមែន ឬយ៉ាងណា ?**

**បុណ្យលើកតម្កើងទុក្ខលំបាកព្រះយេស៊ូ (ថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១០)** *លូកា ២២,១៤-៣៦.២៣,៥៦*

ពេលព្រះយេស៊ូជិតចូលទិវង្គត ព្រះអង្គធ្វើពិធីជប់លៀងចុងក្រោយក្នុងឱកាសបុណ្យចម្លងជាមួយក្រុមសាវ័ក ដើម្បីបង្ហាញថា ព្រះអង្គស្ម័គ្របូជាព្រះជន្មដោយគ្មាននរណាបង្ខំ ។ ពេលរងទុក្ខលំបាកព្រះអង្គ មានព្រះហឫទ័យស្លូតបូត សប្បុរស និងអាណិតអាសូរជានិច្ចចំពោះអ្នកដែលមកចាប់ព្រះអង្គ ចំពោះអ្នកក្បត់ អ្នកជេរប្រមាថ និងវាយព្រះអង្គ អ្នកដែលកាត់ទោសនិងឆ្កាងព្រះអង្គ និងចំពោះអ្នក ដែលនិយាយចំអកព្រះអង្គ ។ ព្រះអង្គបង្ហាញសេចក្ដីស្រឡាញ់ហួសការស្មានរបស់ព្រះបិតាចំពោះមនុស្សលោក ។

ក្នុងនាមមនុស្សលោក ព្រះអង្គបានស្រឡាញ់ព្រះបិតារហូតបូជាព្រះជន្ម ។ ដោយសេចក្ដីស្រឡាញ់នេះ ព្រះអង្គជាស្ពានចម្លងមនុស្សទៅកាន់ព្រះបិតា ។ នារដូវអប់រំពិសេសនេះ ព្រះសហគមន៍សូមឱ្យគ្រីស្ដបរិស័ទគ្រប់ៗរូប និងបងប្អូនដែលនឹងទទួលអគ្គសញ្ញាជ្រមុជទឹកនៅបុណ្យចម្លងខាងមុខរួមគ្នានឹកសញ្ជឹង និងទទួលស្គាល់ព្រះហឫទ័យមេត្តាករុណារបស់ព្រះយេស៊ូដែលសព្វព្រះហឫទ័យបូជាព្រះជន្មធ្វើជាប្រយោជន៍ដល់មនុស្សហើយសូមឱ្យយើងជម្រះចិត្តគំនិត ពីសេចក្ដីអាក្រក់ទាំងឡាយដែលយើងមានដែរ ។

**-តើខ្ញុំត្រូវជម្រះចិត្តពីសេចក្ដីអាក្រក់អ្វីខ្លះ តាមការរស់នៅរបស់ខ្ញុំ ?**



## សិក្ខាសាលានៅមណ្ឌលសកម្មភាពកំពត

កាលពីថ្ងៃទី២០-២១ ខែកុម្ភៈ ឆ្នាំ២០-១០ នៅមណ្ឌលសកម្មភាពកំពត មានរៀបចំសិក្ខាសាលាមួយពីប្រធានបទ "តើខ្ញុំទទួលសញ្ញាអ្វីខ្លះក្នុងជីវិតរស់នៅប្រចាំថ្ងៃ?" ។

សិក្ខាសាលានេះ មានការចូលរួមពីយុវ-ជនយុវនារីចំនួន ១១០នាក់ មកពី៥ព្រះស-ហគមន៍កាតូលិកនៅក្នុងតំបន់ ។

សិក្ខាសាលាមានគោលដៅបីសំខាន់ "ទីមួយ ឱ្យយុវជនយុវនារីចេះចាប់អារម្មណ៍អ្វីដែលខ្លួនបានប្រព្រឹត្ត ។ ទីពីរឱ្យយុវជន យុវ-នារីចាប់អារម្មណ៍អំពីអ្វីៗដែលនៅជុំវិញខ្លួន និងទីបីឱ្យយុវជនយុវនារីចេះទទួលស្គាល់នូវសញ្ញាពីព្រះជាម្ចាស់ ។

លោកផុន សុផល ជាអ្នកសម្របសម្រួលកម្មវិធីយុវជន និងកុមារ នៅឯការិយាល័យយុវជនភូមិភាគភ្នំពេញ មានប្រសាសន៍ថា : "សកម្មភាពយុវជនយុវនារីនៅមណ្ឌលកំពតមានការរីកចម្រើនច្រើនទាំងការចូលរួមការទទួលខុសត្រូវ និងគំនិតយោបល់ ។ ពិសេសជាងនេះទៅទៀត ទោះបីមានយុវជន យុវ-នារីច្រើនជាពុទ្ធបរិស័ទ ប៉ុន្តែពួកគាត់ក៏មានចំណាប់អារម្មណ៍ខ្ពស់ចំពោះសញ្ញារបស់ព្រះជាម្ចាស់ដោយប្រព្រឹត្តអំពើល្អជាមួយគ្រួសារសហគមន៍ និងសង្គម ជារៀងរាល់ថ្ងៃ ។

យុវជនហឿន ចាន់តារា មកពីព្រះសហ-គមន៍ជុំគីរី បានបង្ហាញនូវអារម្មណ៍សប្បាយរីករាយចំពោះអង្គសិក្ខាសិលា ហើយបានធ្វើការរិះគិតពីសញ្ញារបស់ព្រះជាម្ចាស់ក្នុងជីវិតប្រចាំថ្ងៃ ដែលធ្វើឱ្យគាត់មានចិត្តស្រលាញ់គ្រួសាររបស់គាត់កាន់តែខ្លាំងឡើងៗ ។



Photo : Sophal

**ផុន សុផល**

March-2010.qxd 6/10/2010 2:52 PM Page 20

## “ជៀសពីគ្រឿងញៀន ដើម្បីការពារជីវិតអ្នក”

# លេខទូរស័ព្ទដែលត្រូវហៅ បន្ទាន់

*ករណីសង្ស័យគ្រុនផ្តាសាយថ្មី A/H1N1 :

១១៥ / ០១២ ៤៨៨ ៩៨១ / ០៨៩ ៦៦៩ ៩៦៧។

*មណ្ឌលកែប្រែអ្នកញៀនគ្រឿងញៀន :

០១២ ៨១២ ១១៧ / ០១៥ ៨៩៣ ៩៩៩។

*រថយន្តសង្គ្រោះបន្ទាន់ :

-ភ្នំពេញ ០២៣ ៧២៤ ៨៩១។ -សៀមរាប ០៦៣ ៧៦១ ១១៩។

*មជ្ឈមណ្ឌលផ្តល់ឈាម :

០២៣ ២១៥ ៩៤៩។

## ល្បែងកំសាន្ត ផាត់ពណ៌

សូមប្រិយមិត្តជួយផាត់ពណ៌រូបភាពឪពុកខ្លាឃ្មុំជូនអំណោយដល់កូនរបស់ខ្លួនផង !



Photo : jeux-loisirs-enfants

## ការងារប្រចាំខែ

- ថ្ងៃទី០២ មីនា : សម្ពោធវិទ្យាស្ថានព័ត៌វិទ្យា និងកសិកម្ម សន្តប៉ូល នៅអង្គតាសោម ស្រុកត្រាំកក់ ខេត្តតាកែវ។
- ថ្ងៃទី១៣ មីនា : អធិដ្ឋានពិសេសសម្រាប់លោកអភិបាលថ្មីរៀបចំឡើងនៅព្រះសហគមន៍ព្រះកុមារយេស៊ូ បឹងទំពុន រាជធានីភ្នំពេញ។
- ថ្ងៃទី១៣-១៤ មីនា : សំណាក់ធម៌សម្រាប់អ្នកដែលធ្វើជំហានទីពី នៅព្រះសហគមន៍កាតូលិកកោះរកា ភូមិភាគកំពង់ចាម។
- ថ្ងៃទី១៤ មីនា : ជំហានទីមួយ ចំនួន២៥នាក់ រៀបចំធ្វើឡើងនៅព្រះសហគមន៍សន្តយ៉ូសែប នៅជុំគិរី ខេត្តកំពត។
- ថ្ងៃទី១៤ មីនា : ជំហានទីមួយចំនួន ៥នាក់ រៀបចំធ្វើឡើងនៅព្រះសហគមន៍កាតូលិកសន្តអូគូស្ទែរ ខេត្តកំពត។
- ថ្ងៃទី២០ មីនា : លោកអូលីវីយេ ឆ្មិតហស្លែរ ទទួលអគ្គសញ្ញាតែងតាំង ជាអភិបាលកាតូលិកភូមិភាគភ្នំពេញ។
- ថ្ងៃទី២៤ មីនា : ពិធីអភិសេកប្រេងសម្រាប់អគ្គសញ្ញាផ្សេងៗ ដែលត្រូវបានរៀបចំធ្វើឡើងនៅព្រះសហគមន៍សន្តយ៉ូសែប ហៅផ្សារតូច រាជធានីភ្នំពេញ។
- ថ្ងៃទី២៤ មីនា : ប្រជុំទីប្រឹក្សាភូមិភាគកំពង់ចាមនៅព្រះសហគមន៍កាតូលិកកំពង់ចាម។
- ថ្ងៃទី២៤ មីនា : ពិធីបុណ្យខួប ៣០ឆ្នាំ របស់លោកអភិបាលអូស្ការរ៉ូម៉ឺ រៀបចំធ្វើឡើងនៅព្រះសហគមន៍កាតូលិកបាត់ដំបង។
- ថ្ងៃទី២៨ មីនា : បុណ្យលើកតម្កើងការរងទុក្ខរបស់ព្រះយេស៊ូនៅព្រះសហគមន៍កាតូលិកនៅទូទាំងកម្ពុជា។
- រៀងរាល់ថ្ងៃសុក្រ ពីម៉ោង ៤ ទៅ ៥ រសៀល មានធ្វើអធិដ្ឋានតាមដំណើរព្រះឈើឆ្កាង រៀបចំធ្វើនៅព្រះសហគមន៍សន្តយ៉ូសែប ហៅផ្សារតូចរាជធានីភ្នំពេញ។

## សូមអញ្ជើញចូលដោយសេរី

អធិដ្ឋានគេហ្វេសម្រាប់លោក អូលីវីយេ ឆ្មិតហស្លែរ អភិបាលថ្មី ថ្ងៃទី១៩ មីនា ម៉ោង ៧:៣០ ល្ងាច នៅព្រះសហគមន៍កាតូលិក សន្តយ៉ូសែប ហៅផ្សារតូច រាជធានីភ្នំពេញ។